# ឯកសារសង្ខេបអំពី វិស័យកាត់ដេរ ផលិតស្បែកជើង និង ផលិតផលធ្វើដំណើរ នៅកម្ពុជា

ក្បាលលេខ 1

ខែវិច្ឆិកា ឆ្នាំ2022



នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ទិន្នន័យពាក់ព័ន្ធនឹង វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ (GFT) នៅក្នុងប្រទេសកម្ពុជា ត្រូវបានមើលឃើញថាមានភាពរាយប៉ាយ និងប្រមូលផ្ដុំពីប្រភពជាច្រើន។ សេចក្ដីសង្ខេបអំពីវិស័យនេះ មានគោលបំណងបំពេញចន្លោះខ្វះខាតទិន្នន័យឱ្យបានត្រឹមត្រូវ ជាមួយនឹងស្ថិតិផ្លូវការសម្រាប់វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (ឧបសម្ព័ន្ធ 1)។

ឯកសារសង្ខេបនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីស្ថិតិផ្លូវការដែលមានផ្ដល់ជូនជាសាធារណៈ បង្ហាញអំពីនិន្នាការទូទៅ ការអភិវឌ្ឍ និងសមិទ្ធផលរបស់វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដោយមានការផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើផលិតផលធ្វើដំណើរ (TG)។ លើសពីនេះ ឯកសារនេះបង្ហាញឱ្យឃើញអំពីការអភិវឌ្ឍក្រោយជំងឺកូវីដ-19 នៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។ ឯកសារសង្ខេបនេះ បញ្ចប់ដោយសេចក្ដីថ្លែងអំពីបញ្ហាប្រឈមដែលអាចកើតមាន ដែលវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ត្រូវតែដោះស្រាយ ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងនៅក្នុងឆ្នាំបន្តបន្ទាប់។

Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (EuroCham) អង្គការពលកម្មអន្តរជាតិ (ILO) និងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC ពីមុនហៅថាសមាគមរោងចក្រកាត់ដេរនៅកម្ពុជា) សូមថ្លែងអំណរគុណដល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ដែលបានផ្ដល់ស្ថិតិសម្រាប់ ប្រើប្រាស់ជាឯកសារសង្ខេបអំពីវិស័យនេះ។[1]

## ១. សេចក្ដីផ្ដើម

វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ គឺជាសសរទ្រូងរបស់សេដ្ឋកិច្ចកម្ពុជាអស់រយៈពេលជាងពីរទសវត្សរ៍មកហើយ។ វិស័យនេះ គឺជាវិស័យអតិផលកម្លាំងពលកម្ម និងទាក់ទាញតាមលក្ខណៈប្រពៃណីនូវកម្មករនិយោជិតស្ត្រីជាច្រើន៖ 75.9% នៃប្រជាជនមានការងារធ្វើនៅក្នុងសកម្មភាពផលិត "សម្លៀកបំពាក់" គឺជាស្ត្រី[2]។ នៅឆ្នាំ2019 វិស័យនេះចូលរួមចំណែកផ្ដល់ការងារប្រមាណជា 13.8% នៃប្រជាជនមានការងារធ្វើសរុបរបស់កម្ពុជា ក្នុងចំណោមប្រជាជនចំនួន 5.18 លាននាក់។ វិស័យកសិកម្ម និងវិស័យសេវាកម្ម មាន 44% និង 27% នៃប្រជាជនមានការងារធ្វើសរុប។
នៅក្នុងទសវត្សរ៍នៃឆ្នាំ2010-2019 (មុនពេលការរាតត្បាតជាសកលនៃជំងឺកូវីដ-19) វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ មានជាមធ្យម 10% ក្នុងមួយឆ្នាំនៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា។ នៅក្នុងអំឡុងរយៈពេលនេះ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា បានមានការកើនឡើងតាមអត្រាជាមធ្យម 7% ក្នុងមួយឆ្នាំ។ ក្នុងចំណោមកំណើន 7% នោះ កំណើនប្រមាណជាមួយភាគបួនបានមកពីវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។[3]

តួលេខបឋម ឆ្នាំ2021 ពីវិទ្យាស្ថានជាតិស្ថិតិកម្ពុជា (NIS) បង្ហាញថា វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ក៏មានសារៈសំខាន់ផងដែរនៅក្នុងអំឡុងពេលនៃការរាតត្បាតជំងឺ។ វិស័យនេះ មាន 11% នៃសេដ្ឋកិច្ច និងមានប្រមាណជា 50% នៃកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា នៅឆ្នាំ2021 (កំណើន ផសស ពិតរបស់កម្ពុជា គឺត្រូវបានប៉ាន់ស្មានថាមាន 3% នៅឆ្នាំ2021)។ ទោះបីជាធ្វើប្រតិបត្តិការមិនបានពេញសមត្ថភាពក៏ដោយ ក៏តួលេខដ៏ខ្ពស់ទាំងនេះ បង្ហាញថា វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ បាន និងកំពុងដំណើរការយ៉ាងល្អប្រសើរនៅពេញមួយរយៈពេលនៃការរាតត្បាតនៃជំងឺកូវីដ-19 ស្របពេលដែលវិស័យផ្សេងៗទៀតដូចជាវិស័យទេសចរណ៍ ជាដើម ទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

នៅខែមីនា ឆ្នាំ2022 រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ឆ្នាំ2022–2027" ដែលគូសបញ្ជាក់នូវតួនាទីដ៏សំខាន់របស់វិស័យនេះ ក្នុងនាមជាសសរទ្រូងកំណើនចម្បងមួយដែលមានការនាំចេញ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ជាមធ្យមលើសពី 70% នៃទំនិញនាំចេញសរុបរយៈពេលមួយទសវត្សរ៍កន្លងមក។[4] យុទ្ធសាស្ត្រនេះ ក៏សង្កត់ធ្ងន់ទៅលើការចូលរួមចំណែកផ្ទាល់ និងប្រយោលរបស់វិស័យនេះទៅលើជីវភាពរបស់ប្រជាជនកម្ពុជាចន្លោះពី 2.5 ទៅ 3 លាននាក់។

ទោះបីជាវិស័យនេះ គឺជាវិស័យជំរុញសំខាន់មួយនៃវិស័យជំរុញសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជាក៏ដោយ ក៏វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ នៅតែជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងសមត្ថភាពប្រកួតប្រជែង និងចីរភាពរយៈពេលវែង។ ការនាំចេញបច្ចុប្បន្នរបស់វិស័យនេះ គឺពឹងផ្អែកលើការចូលទីផ្សារអនុគ្រោះ ដែលផ្ដល់ជូនដោយសហរដ្ឋអាមេរិក (U.S.) និងសហភាពអឺរ៉ុប (EU) ដែលធ្វើឱ្យការនាំចេញនេះងាយរងគ្រោះទៅនឹងការដកកិច្ចព្រមព្រៀងវិញ ឬទៅនឹងឥទ្ធិពលពីខាងក្រៅផ្សេងទៀត។ ដូច្នេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិត

ស្បែកជើង និងផលិតផលធ្វើដំណើររបស់រដ្ឋាភិបាល បម្រើជាផែនទីបង្ហាញផ្លូវ ដើម្បីបង្កើនសមត្ថភាពរបស់វិស័យ ធ្វើយ៉ាងណាឱ្យវិស័យនេះផលិតនូវផលិតផលគុណតម្លៃបន្ថែមខ្ពស់ជាងមុន មានចីរភាពជាងមុន និងមានលក្ខណៈកាន់តែប្រកួតប្រជែងនៅលើទីផ្សារសកល។ ការបង្កើនសមត្ថភាពនេះ គឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការលើកម្ពស់ពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ត្រឹមឆ្នាំ2027។[5]

លើសពីនេះ កម្ពុជាទើបតែប្រកាសច្បាប់ស្តីពីការវិនិយោគថ្មីកាលពីពេលថ្មីៗកន្លងទៅនេះ (ចូលជាធរមាននៅខែតុលាឆ្នាំ2021) ដោយជំនួសច្បាប់ស្តីពីការវិនិយោគ ឆ្នាំ1994 និងវិសោធនកម្មច្បាប់ស្តីពីការវិនិយោគឆ្នាំ2003។ ច្បាប់ថ្មីឆ្នាំ2021 នេះ ត្រូវបានតាក់តែងឡើង ដើម្បីលើកកម្ពស់វិនិយោគទុនបរទេសនៅក្នុងវិស័យសំខាន់ៗ[6]។ ជាពិសេស ច្បាប់នេះផ្តល់ការលើកទឹកចិត្តដល់គម្រោង ដែលគាំទ្រពិពិធកម្មឧស្សាហកម្ម និងឧស្សាហកម្មបច្ចេកវិទ្យាទំនើប គុណតម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ ឌីជីថល ដូចជាថាមពលបៃតងជាដើម។ ហេតុដូច្នេះ ការលើកទឹកចិត្តដែលបានផ្តល់ជូននៅក្នុងច្បាប់នេះ ក៏ចូលរួមចំណែកដល់គោលបំណងទាំងមូលរបស់កម្ពុជាក្នុងការអភិវឌ្ឍវិស័យកាត់ដេរផលិតស្បែកជើង និងផលិតផលធ្វើដំណើរផងដែរ។

## ២. ទិសដៅនាំចេញ និងទីផ្សារសម្រាប់វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា

### a. ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ

អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា មានវឌ្ឍនភាពគួរឱ្យស្ងើចសរសើរ។ ដូចដែលបានបង្ហាញនៅក្នុងរូបភាព 1 ការនាំចេញបានកើនឡើងពីត្រឹម 962 លានដុល្លារអាមេរិកនៅឆ្នាំ2000 (ក្នុងនោះ 97% គឺសម្លៀកបំពាក់) ដល់ 11.191 លានដុល្លារអាមេរិកនៅឆ្នាំ2021 (ក្នុងនោះ 74% គឺសម្លៀកបំពាក់)។

**រូបភាព 1៖ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ឆ្នាំ2000–2021 (លានដុល្លារអាមេរិក)**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS) និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE)។*

ប្រហែលជាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ជំងឺកូវីដ-19 បានប៉ះពាល់ដល់ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ទោះបីជាមិនធ្ងន់ធ្ងរដូចការរំពឹងទុកក៏ដោយ។ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ធ្លាក់ចុះ 10% នៅឆ្នាំ2020 (ធៀបនឹងឆ្នាំ2019) ហេតុដូច្នេះបង្កើតបានជាអត្រាកំណើនអវិជ្ជមានដំបូងគេចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ2009។

ទោះជាយ៉ាងនេះក្តី យោងតាមស្ថិតិផ្លូវការ[7] ឆ្នាំ2021 បានបង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់អំពីការស្តារឡើងវិញនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ដោយមានតម្លៃនាំចេញកើនឡើង 15% ដល់ 11.2 លានដុល្លារអាមេរិក។ និន្នាការវិជ្ជមាន បានបន្តនៅក្នុងរយៈពេល 8 ខែដំបូងនៃឆ្នាំ2022 ដែលមានកំណើន 28.79% នៅក្នុងការនាំចេញ "សម្លៀកបំពាក់ និងគ្រឿងបន្ថែមសម្លៀកបំពាក់" នៅពេលធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ2021[8]។ ទោះបីជាមានកំណើនយ៉ាងនេះក្តី សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) បានជំរុញឱ្យមានការប្រុងប្រយ័ត្ន ដោយបង្ហាញអំពីការព្រួយបារម្ភទៅលើការថយចុះនៃការបញ្ជាទិញពីបណ្តាប្រទេសលោកខាងលិចពីខែសីហា ឆ្នាំ2022 តទៅ និងយោងទៅលើ"ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល និងការងាកទៅរកឧបសគ្គផ្សេងទៀត ... ដែលអាចមានការពន្យារពេលរហូតដល់ចុងឆ្នាំ ឬយូរជាងនេះ"[9] ។

ចំណែកនៃការនាំចេញ បានមកពីវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ គឺនៅតែមានកម្រិតខ្ពស់នៅឡើយ ដោយសបញ្ជាក់ឱ្យឃើញថា សេដ្ឋកិច្ចកម្ពុជាគឺនៅមិនទាន់ធ្វើពិពិធកម្មបានគ្រប់គ្រាន់នៅឡើយទេ។ អស់រយៈពេលជាងមួយទសវត្សរ៍ ចាប់ពីឆ្នាំ2012 ដល់ 2021 ការនាំចេញនៅក្នុងវិស័យនេះមាន 71% នៃការនាំចេញទំនិញសរុបរបស់កម្ពុជា។ ទោះបីជាបានជួបប្រទះនូវអនុបាតធ្លាក់ចុះនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះក្តី (ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ បានធ្លាក់ចុះដល់ត្រឹម 57% នៃការនាំចេញទំនិញសរុបនៅឆ្នាំ2021) ក៏ការនាំចេញរបស់វិស័យនេះនៅតែជាប្រភពធំជាងគេនៃរូបិយប័ណ្ណបរទេសសម្រាប់កម្ពុជា។[10]

តារាង 1 បង្ហាញអំពីសមាសភាគនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា តារាងនេះបង្ហាញឱ្យឃើញថា ចំណែករបស់ សម្លៀកបំពាក់ មានការថយចុះ ស្របពេលដែលចំណែកនៃផលិតផលធ្វើដំណើរមានការកើនឡើងប្រកបដោយស្ថិរភាព។ និន្នាការនេះ គឺមានភាពច្បាស់លាស់ជាពិសេសនៅក្នុងរយៈពេល 5 ឆ្នាំកន្លងទៅនេះ។ យ៉ាងណាក្តី គួរកត់សម្គាល់ផងដែរថា តម្លៃដាច់ខាតនៃការនាំចេញសម្លៀកបំពាក់គឺនៅតែមានការកើនឡើងនៅក្នុងឆ្នាំ2021 ហើយចំណែកនៃការនាំចេញថយចុះពីសម្លៀកបំពាក់ គឺអាចពន្យល់បានយ៉ាងសាមញ្ញតាមរយៈ កំណើនដ៏ឆាប់រហ័សដែលមានចំពោះការនាំចេញផលិតផលធ្វើដំណើរ និងស្បែកជើង។

ជារួម ក្នុងចំណោមការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរចំនួន 11.2 ប៊ីលានដុល្លារអាមេរិកនៅក្នុងឆ្នាំ2021 ផលិតផលសម្លៀកបំពាក់ បានចូលរួមចំណែក 74% ផលិតផលស្បែកជើង 13% និងផលិតផលធ្វើដំណើរក៏ 13% ផងដែរ។

**តារាង 1៖ សមាសភាគរៀងគ្នានៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ (ឆ្នាំ2016-2021)**

| | 2016 | 2017 | 2018 | 2019 | 2020 | 2021 |
|---|---|---|---|---|---|---|
| ឧស្សាហកម្មកាត់ដេរ (រួមទាំងវាយនភណ្ឌ) | | | | | | |
| នាំចេញ (លានដុល្លារអាមេរិក) | 6,722 | 7,182 | 7,995 | 8,497 | 7,687 | 8,304 |
| កំណើន (%) | 9% | 7% | 11% | 6% | -10% | 8% |
| ចំណែក (%) | 88% | 86% | 83% | 78% | 79% | 74% |

| | | | | | | |
|---|---|---|---|---|---|---|
| ឧស្សាហកម្មផលិតស្បែកជើង | | | | | | |
| នាំចេញ (លានដុល្លារអាមេរិក) | 774 | 880 | 1,040 | 1,265 | 1,117 | 1,392 |
| កំណើន (%) | 17% | 14% | 18% | 22% | -12% | 25% |
| ចំណែក (%) | 10% | 11% | 11% | 12% | 11% | 13% |
| ឧស្សាហកម្មផលិតផលធ្វើដំណើរ | | | | | | |
| នាំចេញ (លានដុល្លារអាមេរិក) | 140 | 268 | 556 | 1,079 | 965 | 1,495 |
| កំណើន (%) | 41% | 91% | 108% | 94% | -11% | 55% |
| ចំណែក (%) | 2% | 3% | 6% | 10% | 10% | 13% |
| សរុបឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ | | | | | | |
| នាំចេញ (លានដុល្លារអាមេរិក) | 7,636 | 8,330 | 9,591 | 10,840 | 9,768 | 11,191 |
| កំណើន (%) | 10% | 9% | 15% | 13% | -10% | 15% |
| ចំណែក (%) | 100% | 100% | 100% | 100% | 100% | 100% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ*

សម្គាល់៖ ឧស្សាហកម្មកាត់ដេរ រួមបញ្ចូល វាយនភណ្ឌ

## b. ទិសដៅនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរចម្បងៗ

ដូចដែលបានបញ្ជាក់ជាភស្តុតាងនៅក្នុងតារាង 2 សហរដ្ឋអាមេរិក គឺជាអ្នកនាំចូលធំបំផុតនៃផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ដែលមាន 43% នៃការនាំចេញសរុបក្នុងឆ្នាំ2021 ពោលគឺកើនឡើងពីត្រឹម 25% នៅឆ្នាំ2016។ សហភាពអឺរ៉ុប (និងអឺរ៉ុបទាំងមូល) នៅតែជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់កម្ពុជា។ ចំណែកនៃការនាំចេញរបស់វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរទៅកាន់ទីផ្សារសហភាពអឺរ៉ុបបានមានការថយចុះ ដែលការថយចុះនេះអាចពន្យល់បានភាគច្រើនដោយសារតែចក្រភពអង់គ្លេសបានដកខ្លួនចេញពីទីផ្សារទោលរបស់សហភាពអឺរ៉ុបនៅឆ្នាំ2020។ ការនាំចេញទៅកាន់ទីផ្សារ ដូចជាប្រទេសជប៉ុន គឺកំពុងមានការកើនឡើង។

**តារាង 2៖ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ** (គិតជាលានដុល្លារអាមេរិក) **កំណើន** (គិតជា %) **និងចំណែកទីផ្សារចម្បង** (គិតជា %)

| ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា (គិតជាលានដុល្លារអាមេរិក) | | | | | | |
|---|---|---|---|---|---|---|
| | **2016** | **2017** | **2018** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | 1,960 | 1,914 | 3,462 | 3,585 | 4,827 | 8,304 |
| ទៅសហភាពអឺរ៉ុប | 1,565 | 3,425 | 4,257 | 3,410 | 2,726 | 8% |
| ទៅប្រទេសផ្សេងៗ | 1,057 | 2,298 | 3,121 | 2,773 | 3,638 | 74% |
| ow ជប៉ុន | - | - | 988 | 869 | 898 | 8,304 |
| ow ចិន | - | - | 348 | 310 | 303 | 8% |
| ow ចក្រភពអង់គ្លេស | - | - | - | - | 641 | 74% |
| សរុប | **4,582** | **7,636** | **10,840** | **9,768** | **11,191** | **74%** |



| អត្រាកំណើននៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ (ពីមួយឆ្នាំទៅមួយឆ្នាំ % r ) | | | | | | |
|---|---|---|---|---|---|---|
| | **2016** | **2017** | **2018** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | - | -6% | 36% | 4% | 35% | 8,304 |
| ទៅសហភាពអឺរ៉ុប | - | 17% | 1% | -20% | -20% | 8% |
| ទៅប្រទេសផ្សេងៗ | - | 17% | 10% | -11% | 31% | 74% |
| ow ជប៉ុន | - | - | 6% | -12% | 3% | 8,304 |
| ow ចិន | - | - | 11% | -11% | -2% | 8% |
| សរុប | **-** | **10%** | **13%** | **-10%** | **15%** | **74%** |
| សរុបឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ | | | | | | |
| | **2016** | **2017** | **2018** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | - | 25% | 32% | 37% | 43% | 8,304 |
| ទៅសហភាពអឺរ៉ុប | - | 45% | 39% | 35% | 24% | 8% |
| ទៅប្រទេសផ្សេងៗ | - | 30% | 29% | 28% | 33% | 74% |
| ow ជប៉ុន | - | - | 9% | 9% | 8% | 8,304 |
| ow ចិន | - | - | 3% | 3% | 3% | 8% |
| ow ចក្រភពអង់គ្លេស | - | - | - | - | 641 | 74% |
| សរុប | | **100%** | **100%** | **100%** | **100%** | **74%** |

*ប្រភព៖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ/វិទ្យាស្ថានជាតិស្ថិតិ។*

ROW សម្តៅទៅលើបណ្តាប្រទេសផ្សេងទៀត។

សម្គាល់៖ នៅថ្ងៃទី31 ខែមករា ឆ្នាំ2020 ចក្រភពអង់គ្លេសបានដកខ្លួនចេញពីសហភាពអឺរ៉ុប និងបានចូលទៅក្នុង រយៈពេលអន្តរកាល។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 រយៈពេលអន្តរកាលបានបញ្ចប់ ហើយចក្រភពអង់គ្លេសបានដកខ្លួនចេញពីទីផ្សារទោល និងសហភាពគយនៃសហភាពអឺរ៉ុបជាផ្លូវការ។ ដូច្នេះ ទីផ្សារសហភាពអឺរ៉ុបនៅរយៈពេលនៃឆ្នាំ2012-2020 សម្តៅទៅលើប្រទេសសមាជិកអឺរ៉ុបចំនួន 28 ប្រទេស ប៉ុន្តែចាប់ពីឆ្នាំ2021 តទៅ ទីផ្សារសហភាពអឺរ៉ុបសម្តៅទៅលើប្រទេសសមាជិកអឺរ៉ុបចំនួន 27 ប្រទេស (មិនមានចក្រភពអង់គ្លេស)។

ចំណុចសំខាន់ត្រូវកត់សម្គាល់គឺថា ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរទៅកាន់ទីផ្សារសហភាពអឺរ៉ុបានធ្លាក់ចុះ 20% នៅឆ្នាំ2020 និងបន្តធ្លាក់ចុះ 20% ទៀតនៅឆ្នាំ2021 ដែលជាការចង្អុលបង្ហាញយ៉ាងជាក់ច្បាស់អំពីការប៉ះពាល់អវិជ្ជមានដោយសារឥទ្ធិពលនេះ៖

i. ការរាតត្បាតជាសកលនៃជំងឺកូវីដ-19។
ii. ការដកចេញដោយផ្នែកនៃការចូលទីផ្សារអឺរ៉ុបដោយការអនុអនុគ្រោះពន្ធ និងកូតា នៅក្រោមគំនិតផ្តួចផ្តើមអ្វីគ្រប់យ៉ាងក្រៅពីអាវុធ (EBA)(ដែលបានប្រកាសដោយសហភាពអឺរ៉ុបនៅខែសីហា ឆ្នាំ2020)។[11] ការដកចេញដោយផ្នែកនៃប្រព័ន្ធអនុគ្រោះប្រមាណជា 20% នៃការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប ប៉ះពាល់ដល់ផ្នែកពន្ធចំនួន 64 ផ្នែក។ ក្នុងចំនោមផ្នែកពន្ធចំនួន 64 ដែលរងផលប៉ះពាល់នោះ ពន្ធចំនួន 5 ពាក់ព័ន្ធនឹងផលិតផលធ្វើដំណើរ 13 ពាក់ព័ន្ធនឹងផលិតផលស្បែកជើង និង 46 ពាក់ព័ន្ធនឹងផលិតផលសម្លៀកបំពាក់ ។ កម្ពុជានៅតែនាំចេញផលិតផលដែលរងផលប៉ះពាល់ទាំងនោះទៅកាន់ទីផ្សារសហភាពអឺរ៉ុបដដែល ប៉ុន្តែទំនិញទាំងនោះត្រូវជាប់ពន្ធទូទៅដែលអនុវត្តចំពោះសមាជិកណាមួយផ្សេងទៀតនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ការនាំចេញនៅសល់ 80% ទៀតរបស់កម្ពុជា នៅតែមានការអនុគ្រោះ (ការអនុគ្រោះពន្ធ និងកូតា) ក្នុងការចូលទៅទីផ្សារសហភាពអឺរ៉ុប។

ជាលទ្ធផលនៃបញ្ហាខាងលើ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប បានធ្លាក់ចុះពី 4,257 លានដុល្លារអាមេរិកនៅឆ្នាំ2019 ទៅ 3,410 លានដុល្លារអាមេរិកនៅឆ្នាំ2020 (-20%) និងថយចុះបន្ថែមទៀតដល់ 2,726 លានដុល្លារអាមេរិកនៅឆ្នាំ2021 (ជាការថយចុះ -20% ថែមទៀត)។ ដូចដែលបានបង្ហាញនៅក្នុងចំណុចខាងលើគួរកត់សម្គាល់ផងដែរថា ការធ្លាក់ចុះទៅលើការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុបនៅឆ្នាំ2021 ភាគច្រើនបំផុត គឺដោយសារតែការដកខ្លួនចេញរបស់ចក្រភពអង់គ្លេសពីប្លុកសហភាពអឺរ៉ុបនៅឆ្នាំ2021

(ប្រទេសសមាជិកសហភាពអឺរ៉ុបមាន 28 ប្រទេសនៅឆ្នាំ2020 ធៀបនឹងប្រទេសសមាជិកសហភាពអឺរ៉ុប មាន 27 ប្រទេសនៅឆ្នាំ2021)។[12] ហេតុដូច្នេះ ការធ្លាក់ចុះជាក់ស្តែងទៅលើការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរទៅកាន់ទីផ្សារសហភាពអឺរ៉ុប ដកជាមួយនឹងការដកខ្លួនរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប គឺមានត្រឹមតែ 1.26% ប៉ុណ្ណោះនៅឆ្នាំ2021។

កម្ពុជាមានលទ្ធភាពក្នុងការជម្នះបញ្ហាខ្លះៗនៃបញ្ហាប្រឈមទាំងនេះ តាមរយៈការការបង្វែរការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់ខ្លួនទៅកាន់ទីផ្សារផ្សេងទៀត ជាពិសេស សហរដ្ឋអាមេរិក។ នៅត្រង់ចំណុចនេះ ចំណែកនៃការនាំចេញបានកើនឡើងដល់ 43% នៅឆ្នាំ2021 ពោលគឺកើនឡើងពី 37% នៅឆ្នាំ2020 ដូច្នេះធ្វើឱ្យសហរដ្ឋអាមេរិកក្លាយជាទីផ្សារប្រទេសធំបំផុតតែមួយគត់សម្រាប់ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា។ ស្របពេលជាមួយគ្នានេះដែរ ចំណែននៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជាទៅកាន់ទីផ្សារផ្សេងទៀតក្រៅពី សហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប បានកើនឡើងដល់ 33% នៅឆ្នាំ2021 ពោលគឺកើនឡើងពីត្រឹម 28% ប៉ុណ្ណោះនៅឆ្នាំ2020។ ការអភិវឌ្ឍនេះ ជាថ្មីម្តងទៀត អាចដោយសារតែមកពី "ឥទ្ធិពលនៃការចរចាបញ្ចប់សមាជិកភាពអង់គ្លេសក្នុងសហភាពអឺរ៉ុប (Brexit)". ប្រសិនបើចក្រភពអង់គ្លេស ត្រូវបានបញ្ចូលទៅក្នុងការប្រៀបធៀបឆ្នាំ2021 ចំណែកនៃការនាំចេញរបស់វិស័យនេះ ធៀបនឹងទីផ្សារ "ប្រទេសផ្សេងទៀត (ROW)" នៅតែស្ទើរតែជិតស្មើគ្នាទៅនឹងឆ្នាំ2020។ គួរកត់សម្គាល់ផងដែរថា ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2021 កម្ពុជា (និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងមិនសូវអភិវឌ្ឍន៍ផ្សេងទៀត) នៅតែអាចទទួលបានការអនុគ្រោះក្នុងការចូលទីផ្សារចក្រភពអង់គ្លេសបាន (នៅក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់ចក្រភពអង់គ្លេស (UK Generalized Scheme of Preferences)។[13]

ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា បានកើនឡើង 15% នៅឆ្នាំ2021 ដែលឡើងទៅដល់ 11.2 ប៊ីលានដុល្លារអាមេរិក។ បន្ទាប់មក ការនាំចេញនេះបានកើនឡើង 25% ទៀតក្នុងអំឡុងត្រីមាសទី 1 ឆ្នាំ2022 (ធៀបទៅនឹងត្រីមាសទី 1 ឆ្នាំ2021)[14]។ ដោយសារតែបញ្ហាប្រឈមសកលដែលបានកើនឡើងក្នុងអំឡុងឆ្នាំ2020 និងឆ្នាំ2021 កំណើននេះគួរតែត្រូវបានចាត់ទុកថាជាការអភិវឌ្ឍប្រកបដោយភាពវិជ្ជមាន។

មូលហេតុមួយចំនួននៅពីក្រោយកំណើននេះ មានដូចខាងក្រោម៖

i. ប្រទេសមីយ៉ាន់ម៉ា បាន និងកំពុងទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងនាមជាទិសដៅនាំចូលទំនិញ ដោយមានការបញ្ជាទិញមួយចំនួនផ្លាស់ប្តូរមកកាន់ប្រទេសកម្ពុជា
ii. ការគ្រប់គ្រងជំងឺកូវីដ-19 ប្រកបដោយសមត្ថភាពរបស់កម្ពុជា
iii. ការពិតដែលថាមិនមានបញ្ហារាំងស្ទះធំដុំទៅលើសេវាភស្តុភារកម្មសម្រាប់ការផ្គត់ផ្គង់វត្ថុធាតុដើមពីប្រទេសចិនក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺឡើយ។

យ៉ាងណាមិញ ក៏នៅមានទិដ្ឋភាពដែលអាចព្យាករណ៍បាន និងមានលក្ខណៈវិជ្ជមានដែលកម្ពុជាអាចពង្រីក និងធ្វើពិពិធកម្មទីផ្សារនាំចេញរបស់ខ្លួន តាមរយៈការទាញយកផលប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ដែលទើបតែអនុវត្តកាលពីពេលថ្មីៗកន្លងទៅនេះ។ កិច្ចព្រមព្រៀងនេះរួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) និង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)[15] ដែលកិច្ចព្រមព្រៀងទាំងពីរនេះបានចូលជាធរមាននៅខែមករា ឆ្នាំ2022។ លើសពីនេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA) នឹងចូលជាធរមាននៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2022 បន្ទាប់ពីបានចុះហត្ថលេខានៅថ្ងៃទី26 ខែតុលា ឆ្នាំ2022។

ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន បច្ចុប្បន្ននេះ កម្ពុជាកំពុងតែធ្វើការសិក្សាសមិទ្ធលទ្ធភាពសម្រាប់កិច្ចព្រមព្រៀងបន្ថែម ដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ជប៉ុន (CJFTA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ឥណ្ឌា (CIFTA) និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-បង់ក្លាដែស (CBFTA)។ ប្រសិនបើបានអនុម័តរួចរាល់កិច្ចព្រមព្រៀងទាំងនេះ គឺត្រូវបានរំពឹងទុកថានឹងបន្តបើកឱកាសសម្រាប់ការនាំចេញនៃ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ក៏ដូចជាទំនិញនាំចេញផ្សេងទៀតផងដែរ។

ពាក់ព័ន្ធនឹងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ការសិក្សាកាលពីពេលថ្មីៗមួយរបស់ធនាគារពិភពលោក បានដាក់ចំណាត់ថ្នាក់កម្ពុជានៅក្នុងចំណោមប្រទេសសមាជិកកំពូលទាំងបី (វៀតណាម ជប៉ុន កម្ពុជា) ដែលទំនងជាទទួលបាននូវការនាំចេញកើនឡើងខ្លាំង ដោយសារតែ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ នៅទូទាំងវិស័យមួយចំនួន។ ដូច្នេះ ឥទ្ធិពលនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ អាចនឹងនៅមានកម្រិត ដោយសារមូលហេតុផ្សេងទៀត ព្រោះតែការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ នាពេលបច្ចុប្បន្ននេះ គឺបានកំណត់ទិសដៅជាចម្បងទៅកាន់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។[16]

## c. ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ក្នុងនាមជាចំណែកមួយនៃទីផ្សារសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរសកល

ដូចដែលបានបញ្ជាក់ជាភស្តុតាងនៅក្នុងតារាង 3 ខាងក្រោម ចិន នៅតែជាអ្នកនាំចេញកំពូលនៃផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរសកល ដោយមានការនាំចេញ 32.8% នៅឆ្នាំ2021។ បន្ទាប់មក មានប្រទេសវៀតណាម 8.5% និងបង់ក្លាដែសមាន 4.7% នៃទីផ្សារសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរសកល។

**តារាង 3. អ្នកនាំចេញកំពូលទាំង 15 នៃផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ (ក្នុងចំណោមប្រទេសនាំចេញកំពូលទាំង 15) ជាចំណែកនៃទីផ្សារផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរពិភពលោក** (គិតជា %) – កម្ពុជាឈរនៅចំណាត់ថ្នាក់លេខ 9 នៅឆ្នាំ2021

| | 1995 | 2005 | 2015 | 2018 | 2019 | 2020 | 2021 |
|---|---|---|---|---|---|---|---|
| ប្រទេសនាំចេញ | 57.1 | 63.9 | 71.7 | 66.8 | 66.2 | 65.7 | 67.3 |
| 1. ចិន | 14.7 | 26.1 | 39.2 | 33.1 | 32.0 | 31.8 | 32.8 |
| 2. វៀតណាម | 0.7 | 2.1 | 5.6 | 6.9 | 7.5 | 7.6 | 8.5 |
| 3. បង់ក្លាដែស | 1.0 | 1.9 | 4.3 | 4.8 | 4.8 | 4.5 | 4.7 |
| 4. ទួគី | 2.7 | 3.1 | 2.5 | 2.5 | 2.5 | 2.6 | 2.6 |
| 5. ឥណ្ឌា | 2.2 | 2.7 | 3.4 | 3.0 | 3.0 | 2.5 | 2.5 |
| 6. ឥណ្ឌូនេស៊ី | 2.4 | 1.7 | 1.9 | 2.1 | 1.9 | 2.1 | 2.0 |
| 7. ម៉ាឡេស៊ី | 1.1 | 0.7 | 0.8 | 0.9 | 0.8 | 1.6 | 1.9 |
| 8. ហុងកុង តំបន់រដ្ឋបាលពិសេស ចិន | 14.7 | 9.9 | 4.1 | 3.0 | 2.7 | 2.2 | 1.8 |
| 9. កម្ពុជា | **0.1** | **0.7** | **1.0** | **1.4** | **1.4** | **1.7** | **1.3** |
| 10. ប៉ាគីស្ថាន | 0.7 | 1.0 | 0.8 | 0.9 | 0.9 | 1.0 | 1.1 |
| 11. ស្រីលង្កា | 0.8 | 0.8 | 0.7 | 0.8 | 0.8 | 0.7 | 0.7 |
| 12. ថៃ | 3.3 | 1.3 | 0.7 | 0.7 | 0.7 | 0.9 | 0.7 |
| 13. មិកស៊ិក | 1.3 | 2.0 | 0.8 | 0.7 | 0.7 | 0.7 | 0.7 |
| 14. ម៉ារ៉ុក | 0.8 | 0.8 | 0.5 | 0.6 | 0.6 | 0.6 | 0.6 |
| 15. មីយ៉ាន់ម៉ា | 0.0 | 0.2 | 0.1 | 0.7 | 0.8 | 0.9 | 0.6 |
| ផ្សេងៗ | 42.9 | 36.1 | 28.3 | 33.2 | 33.8 | 34.3 | 32.7 |
| ពិភពលោក | **100** | **100** | **100** | **100** | **100** | **100** | **100** |

*ប្រភព៖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) (បានចូលមើលនៅថ្ងៃទី16 ខែកក្កដា ឆ្នាំ2022)។ ចំណែកភាគរយ គឺត្រូវបានគណនាដោយផ្អែកលើតម្លៃនាំចេញរបស់ប្រទេស។*

សម្គាល់៖ យោងតាមការចាត់ថ្នាក់ប្រទេសបច្ចុប្បន្នភាពរបស់ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) (ចុះថ្ងៃទី12 ខែមេសា ឆ្នាំ2022)។

កម្ពុជាជាប់ចំណាត់ថ្នាក់លេខ 9 ក្នុងចំណោមអ្នកនាំចេញកំពូលទាំង 15 នៃផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ដែលតំណាងឱ្យ 1.3% នៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរសកល នៅឆ្នាំ2021។ ទោះជាយ៉ាងនេះក្តី យោងតាមស្ថិតិដែលចុះផ្សាយដោយសារព័ត៌មានក្នុងស្រុក ដែលទំនងជាចេញពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ចំណែកនាំចេញសកលរបស់កម្ពុជា គឺត្រូវបានជឿថាមានកម្រិតខ្ពស់ជាងនេះ បើធៀបនឹងតួលេខរបស់ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD)។ ជាលទ្ធផល ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ក៏អាចនឹងត្រូវបានវាយតម្លៃទាបតាមរយៈការចាត់ថ្នាក់នេះផងដែរ។

អាស៊ី នៅតែជាតំបន់ផលិតសម្លៀកបំពាក់ចម្បងរបស់ពិភពលោក (ដែលជំរុញមួយផ្នែកធំដោយប្រទេសចិន)។ នៅឆ្នាំ2019 តំបន់អាស៊ីបានរួមចំណែក 55% នៃការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់សកល។ វិស័យកាត់ដេរ (រួមទាំង វាយនភណ្ឌ) និងផលិតស្បែកជើង នៅតែជាវិស័យចូលរួមចំណែកដ៏សំខាន់ចំពោះសេដ្ឋកិច្ចប្រទេសក្នុងតំបន់អាស៊ីជាច្រើន ដែលផ្តល់ការងារដល់កម្មករនិយោជិតប្រមាណជា 60 លាននាក់នៅក្នុងតំបន់ និងផ្តល់ការងារដោយប្រយោលដល់ប្រជាជនរាប់លាននាក់បន្ថែមទៀត។[17]

## ៣. ការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលទើបអនុម័តថ្មីៗនៅក្នុង វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ

### a. វិនិយោគទុនថ្មី

វិនិយោគផ្ទាល់ពីបរទេស គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ ប្រការនេះ គឺមានលក្ខណៈជាក់ស្តែងជាពិសេសសម្រាប់ការវិនិយោគផ្ទាល់ពីបរទេសទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលជាកត្តាជំរុញស្នូលក្នុងការបង្កើតការងារ និងកំណើនផលិតផលក្នុងស្រុកសរុប។

ជំងឺកូវីដ-19 បានបង្ហាញឱ្យឃើញអំពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជា។ យោងតាមក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) ឆ្នាំ2020 មាននូវគម្រោងវិនិយោគចំនួន 154 គម្រោងដែលបានអនុម័តនៅទូទាំងវិស័យ[18] ដែលស្មើនឹងទឹកប្រាក់ចំនួន 7.5 ប៊ីលានដុល្លារអាមេរិកនៃទ្រព្យសកម្មរយៈពេលវែង ដែលកត់សម្គាល់នូវការថយចុះ 8.0% ធៀបទៅនឹងឆ្នាំ2019។ ក្នុងចំណោមគម្រោងវិនិយោគចំនួន 154 គម្រោងដែលបានអនុម័តនៅឆ្នាំ2020 គម្រោងចំនួន 80 គឺវិនិយោគទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលស្មើនឹងទឹកប្រាក់ចំនួន 371 លានដុល្លារអាមេរិកនៃទ្រពញយសកម្មរយៈពេលវែង ដែលមានការថយចុះ 34% ធៀបទៅនឹងឆ្នាំ2019។ ស្រដៀងគ្នានេះដែរ គម្រោងវិនិយោគថ្មីៗចំនួន 108 គម្រោង គឺត្រូវបានអនុម័តនៅទូទាំងវិស័យនៅឆ្នាំ2021 ដែលស្មើនឹងទឹកប្រាក់ចំនួន 1.7 ប៊ីលានដុល្លារអាមេរិក តំណាងឱ្យការថយចុះ 77% ធៀបទៅនឹងឆ្នាំ2020។ ក្នុងចំណោមគម្រោងវិនិយោគចំនួន 108 គម្រោងដែលបានអនុម័តនៅឆ្នាំ2021 គម្រោងចំនួន 63 គឺវិនិយោគទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលស្មើនឹងទឹកប្រាក់ចំនួន 291 លានដុល្លារអាមេរិកនៃទ្រព្យសកម្មរយៈពេលវែង ដែលមានការថយចុះ 21% ធៀបទៅនឹងឆ្នាំ2020។

ទោះបីជាមានការថយចុះយ៉ាងនេះក្តី ក៏ស្ថិតិរបស់ក្រុមប្រឹក្សាវិនិយោគកម្ពុជា បច្ចុប្បន្នកំពុងបង្ហើបឱ្យឃើញអំពីការស្តារឡើងវិញ។ ត្រីមាសទី 1 ឆ្នាំ2022 មានការអនុម័តទៅលើគម្រោងវិនិយោគចំនួន 24 លើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលស្មើនឹងទឹកប្រាក់ចំនួន 114 លានដុល្លារអាមេរិកនៃទ្រព្យសកម្មរយៈពេលវែង ដូច្នេះបង្ហាញឱ្យឃើញពីការកើនឡើង 110% ធៀបទៅនឹងត្រីមាសទី 1 ឆ្នាំ2021។

ដើម្បីលើកកម្ពស់លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបានកាន់តែល្អប្រសើរ កម្ពុជា បានដាក់ចេញនូវច្បាប់ស្តីពីការវិនិយោគថ្មី (ចូលជាធរមានតាំងពីខែតុលា ឆ្នាំ2021) ដែលផ្តល់នូវក្របខ័ណ្ឌច្បាប់កាន់តែល្អប្រសើរសម្រាប់វិនិយោគិនបរទេស[20]។ ច្បាប់នេះលើកកម្ពស់ដល់ការធ្វើពិពិធកម្មឧស្សាហកម្ម និងផ្តល់ការលើកទឹកចិត្តសារពើពន្ធចំពោះវិស័យអាទិភាព។ ច្បាប់នេះគឺជាការឆ្លើយតបមួយផ្នែកទៅនឹងបរិបទភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចដែលមានការប្រែប្រួលរបស់កម្ពុជា និងត្រូវបានតាក់តែងឡើងដើម្បីជួយដល់កម្ពុជាក្នុងការធ្វើមូលធននីយកម្មទៅលើបដិវត្តន៍ឧស្សាហកម្ម 4.0 និងនិន្នាការផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្លាស់ប្តូរទៅជាឌីជីថល។



វិស័យវិនិយោគដែលទទួលបានការលើកទឹកចិត្តរួមមាន៖

i. ឧស្សាហកម្មបច្ចេកវិទ្យាទំនើប គុណតម្លៃបន្ថែមកម្រិតខ្ពស់ នវានុវត្តន៍ និងប្រកួតប្រជែងខ្លាំង
ii. ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិក មេកានិច និងគ្រឿងម៉ាស៊ីន ឧស្សាហកម្មឌីជីថល
iii. ថាមពលបៃតង និង
iv. ឧទ្យានឧស្សាហកម្ម/ឧទ្យានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។[21]

ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគមាន លក្ខណសម្បត្តិគ្រប់គ្រាន់ (QIP) រួមមាន៖

i. ការលើកលែងពន្ធលើប្រាក់ចំណេញសម្រាប់រយៈពេលរហូតដល់ 9 ឆ្នាំ (អាស្រ័យលើវិស័យ និងសកម្មភាពវិនិយោគ)។
ii. គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ឧស្សាហកម្មនាំចេញ និង គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលគាំទ្រដល់ឧស្សាហកម្មនាំចេញ គឺមានសិទ្ធិទទួលបានការលើកលែង (ពន្ធគយ ពន្ធពិសេស និងអាករលើតម្លៃបន្ថែម) សម្រាប់ការនាំចូលគ្រឿងសំណង់ សម្ភារៈសំណង់ បរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។
iii. ការលើកលែងអាករលើតម្លៃបន្ថែម (VAT) សម្រាប់ការទិញធាតុចូលផលិតក្នុងស្រុកសម្រាប់ការអនុវត្តគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

វិនិយោគិននៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក៏នឹងទទួលបានដំណើរការចុះបញ្ជីកាន់តែរហ័ស ដោយពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគនឹងអនុម័តក្នុងរយៈពេល 20 ថ្ងៃធ្វើការ (បរ្បិនបើគម្រោងដែលបានស្នើឡើង មិនមែនស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន)។[22] រដ្ឋបាលរាជធានី/ខេត្ត គឺត្រូវបានអនុញ្ញាតឱ្យធ្វើការអនុម័តទៅលើម្រោងវិនិយោគដែលស្មើនឹងទឹកប្រាក់ចំនួន 5 លានដុល្លារអាមេរិក តាមរយៈ "អនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត"។ អភិបាល/អភិបាលក្រុងពាក់ព័ន្ធ ជាធម្មតាគឺជាប្រធាននៃអនុគណៈកម្មាធិការនេះ។[23]

**រូបភាព 2៖ ការវិនិយោគផ្ទាល់ពីបរទេសទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលបានអនុម័ត នៅឆ្នាំ2012–2021 (គិតជាទ្រព្យសកម្មរយៈពេលវែង លានដុល្លារអាមេរិក)**




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) / ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB)។*

## b. ប្រទេសដើមកំណើតសម្រាប់ការវិនិយោគផ្ទាល់ពីបរទេសទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ

ទ្រព្យសកម្មនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ គឺត្រូវបានកាន់កាប់ជាកម្មសិទ្ធិមួយផ្នែកធំដោយជនបរទេស។ អង្គការពលកម្មអន្តរជាតិបានអង្កេតឃើញថា ចាប់ពីឆ្នាំ2017-2018 រោងចក្រកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ 97% ដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា គឺជាកម្មសិទ្ធិរបស់បរទេស។ ចំណែកនេះ គឺមានត្រឹមតែ 54% ប៉ុណ្ណោះនៅក្នុងប្រទេសវៀតណាម 45% នៅឥណ្ឌូនេស៊ី និងហ្វីលីពីន 34% នៅថៃ 20% នៅបង់ក្លាដែស 20% នៅចិន 17% នៅស្រីលង្កា និង 12% នៅម៉ាឡេស៊ី។[24] ចំណែកកម្រិតទាបនៃកម្មសិទ្ធិបរទេសនៅក្នុងប្រទេសដទៃទៀត អាចដោយសារតែមកពីការពិតដែលថាបណ្តាប្រទេសទាំងនោះមានបទប្បញ្ញត្តិតឹងរ៉ឹងជាងទលើលទ្ធភាពទទួលបានសិទ្ធិលើទ្រព្យសម្បត្តិ នៅពេលប្រៀបធៀបជាមួយនឹងវិធីសាស្ត្រសេរីដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។[25]

ដូចដែលបានឃើញនៅក្នុងរូបភាព 3 ចិននៅតែជាប្រភពនាំមុខគេនៃការវិនិយោគបរទេសមកលើ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ដែលមាន 66.3% នៃវិនិយោគទុនថ្មីនៅឆ្នាំ2021។ ចិនដីគោក បន្ទាប់មកមានតៃវ៉ាន់ (19.7%) និងហុងកុង (8.4%)។ កម្ពុជា គឺត្រូវបានរំពឹងទុកថានឹងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសបន្ថែមទៀតនាពេលអនាគត។ បរិយាកាសវិនិយោគ និងស្ថានភាពសេដ្ឋកិច្ច នៅតែមានស្ថិរភាព ថ្លៃដើមកម្លាំងពលកម្មនៅតែមានលក្ខណៈសមរម្យ។ ការវិនិយោគ ឯកជនទាំងនេះទៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរដែលត្រូវការកម្លាំងពលកម្មច្រើន នឹងនៅតែមានតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារការងាររបស់កម្ពុជា ជាពិសេសសម្រាប់ស្ត្រីកម្ពុជា។ គិតត្រឹមដំណាច់ឆ្នាំ2021 កម្មករនិយោជិតស្ត្រីមាន 82% នៃកម្លាំងសរុបនៃពលកម្មវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា។[26]

**រូបភាព 3៖ ការវិនិយោគអនុម័តថ្មីថ្មោងទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរតាមប្រទេសដើមកំណើត** (នៅឆ្នាំ2021 គិតជា%)




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) / ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB)។*

* កំណត់សម្គាល់ចំពោះរូបភាព 3 - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មិនត្រឹមតែអនុម័តការវិនិយោគផ្ទាល់ពីបរទេសប៉ុណ្ណោះទេ តែថែមទាំងការវិនិយោគឯកជនកម្ពុជាផងដែរ។

# ៤. ការងារ និងប្រាក់ឈ្នួល

## a. ស្ថានភាពនៃការងារ និងប្រាក់ឈ្នួល

យោងតាមស្ថិតិរបស់ក្រសួងពាណិជ្ជកម្ម រោងចក្រកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរដែលបានចុះបញ្ជីជាផ្លូវការបានផ្តល់ការងារដល់កម្មករនិយោជិតចំនួន 715,121 នាក់[27] នៅឆ្នាំ2019។ ត្រឹមឆ្នាំ2021 ចំនួននេះបានធ្លាក់ចុះមក 671,509 នាក់។ ដូច្នេះ កម្មករនិយោជិតជិត 45,000 នាក់ បានបាត់បង់ការងារនៅចន្លោះឆ្នាំ2020 និង 2021 ដែលបណ្តាលមកពីការបិទ ឬការផ្អាករោងចក្រពាក់ព័ន្ធនឹងការឆ្លងរាលដាលនៃជំងឺ[28]។



កម្មករនិយោជិតមួយចំនួននៃកម្មករនិយោជិត 45,000 នាក់នេះ អាចនឹងមិនត្រលប់ចូលមកក្នុងកម្លាំងពលកម្មវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរទៀតទេ។ នៅដើមឆ្នាំ2022 ប្រធានសមាគមផលិតស្បែកជើងកម្ពុជា បានសង្កេតឃើញថា ទោះបីជា "ផលិតកម្មនៅរោងចក្រមានស្រាប់មានការកើនឡើង និងរោងចក្រថ្មីៗបានបើកដំណើរការក៏ដោយ ក៏នៅតែមានកង្វះខាតកម្មករនិយោជិតរោងចក្រ និង កម្មករនិយោជិតដែលមានជំនាញជាក់លាក់ ជាពិសេសនៅតំបន់ជាយក្រុង"[29]។ ការស្នើឡើងរបស់លោកគឺថា មួយចំណែកនៃកម្មករនិយោជិតទាំងនោះដែលបានដាក់ឱ្យឈប់សម្រាក ឬបញ្ឈប់ពីការងារនៅក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺ មិនបានត្រលប់មកធ្វើការវិញទេ ដោយផ្លាស់ប្តូរទៅបម្រើការងារនៅវិស័យផ្សេង ឬស្វែងរកការងារនៅកន្លែងផ្សេង។

ប្រាក់ចំណូលប្រចាំខែជាមធ្យម (ប្រាក់ចំណូលសុទ្ធក្រោយកាត់ពន្ធ) របស់កម្មករនិយោជិតនៃ វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ បាន និងកំពុងមានស្ថិរភាព ថែមទាំងមានការកើនឡើងពី 232 ដុល្លារអាមេរិកក្នុងមួយខែ (ឆ្នាំ2019) ដល់ 234 ដុល្លារអាមេរិក (ឆ្នាំ2020) ដល់ 256 ដុល្លារអាមេរិក (ឆ្នាំ2021)[30]។ ដូច្នេះ កម្មករនិយោជិតម្នាក់នៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ រកចំណូលបានបន្ថែម 9.7% ក្នុងមួយខែនៅឆ្នាំ2021 ធៀបនឹងឆ្នាំ2020។

ស្ថិរភាពនៃប្រាក់ចំណូលប្រចាំខែ អាចដោយសារតែការបន្តកើនឡើងនៃប្រាក់ឈ្នួលប្រចាំខែអប្បបរមាតាមបទប្បញ្ញត្តិដែលបានកំណត់សម្រាប់វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។ ប្រាក់ឈ្នួលនេះ ត្រូវបានកំណត់នៅ US$ 190/192/194/200 រៀងគ្នាសម្រាប់ឆ្នាំ 2020/21/22/23[31]។ ដូចដែលបានឃើញនៅក្នុងរូបភាព 4 ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិ ដែលបច្ចុប្បន្ន អនុវត្តចំពោះតែវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរប៉ុណ្ណោះ បាន និងកំពុងកើនឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ2003 មក ដោយមានកំណើន 12.7% (ជាមធ្យម) ជារៀងរាល់ឆ្នាំចន្លោះឆ្នាំ2003-2022។ ការកើនឡើងនេះ គឺផ្អែកលើការពិគ្រោះយោបល់ត្រីភាគី ដែលត្រូវបានសម្របសម្រួលដោយក្រុមប្រឹក្សាប្រាក់ឈ្នួលអប្បបរមា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អមជាមួយនឹងតំណាងកម្មករនិយោជិត និយោជក និងរដ្ឋាភិបាល។

**រូបភាព 4៖ ការងារ ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិ និងប្រាក់ឈ្នួលប្រចាំខែជាមធ្យមធម្មតា (ប្រាក់ឈ្នួលសុទ្ធក្រោយកាត់ពន្ធ) នៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។**




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានជាតិស្ថិតិ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់កម្ពុជា។*

តាមរយៈការធ្វើនិយតកម្មសម្រាប់អតិផរណា អត្រាកំណើននៃប្រាក់ចំណូលមធ្យមពិតសម្រាប់ពេលបច្ចុប្បន្ននេះ គឺមានស្ថិរភាព។ ប្រាក់ចំណូលប្រចាំខែមធ្យមពិតរបស់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ គឺត្រឹមតែ 217 ដុល្លារអាមេរិកប៉ុណ្ណោះ[32] នៅឆ្នាំ2020 និងបានកើនឡើងដល់ 232 ដុល្លារក្នុងមួយខែនៅឆ្នាំ2021។ ការកើនឡើងនេះប្រាក់ចំណូលពិត អាចដោយសារតែអត្រាអតិផរណាមានកម្រិតទាបនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរយៈពេលនោះ។

អតិផរណា បាន និងកំពុងមានការកើនឡើងចាប់តាំងពីដើមឆ្នាំ2022 មក ប៉ុន្តែ និងកាលពីពេលថ្មីៗនេះ បានឈានដល់កម្រិតកំណត់ត្រាខ្ពស់ក្នុងរយៈពេល 10 ឆ្នាំចុងក្រោយនេះ។ ស្ថិតិផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ បង្ហាញថា សន្ទស្សន៍តម្លៃទំនិញអ្នកប្រើប្រាស់ (CPI) នៅកម្ពុជា បានមានការកើនឡើង 5.9% នៅត្រីមាសទី 1 ឆ្នាំ2022 បើធៀបទៅនឹងត្រីមាសទី 1 ឆ្នាំ2021។ ឥទ្ធិពលមិនល្អនៃអតិផរណាមកលើប្រាក់ចំណូលពិតរបស់កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ នៅមិនទាន់មានការផ្ទៀងផ្ទាត់នៅឡើយទេ ទោះបីជាការគណនាបណ្តោះអាសន្នដោយផ្អែកលើស្ថិតិផ្លូវការបង្ហាញអំពីការថយចុះ 1.5% ទៅលើប្រាក់ចំណូលប្រចាំខែពិតនៅត្រីមាសទី 1 ឆ្នាំ2022 (US$ 228) បើធៀបទៅនឹងត្រីមាសទី 1 ឆ្នាំ2021 (US$ 232)។

## b. ការប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាប្រចាំខែតាមបទប្បញ្ញត្តិនៅក្នុងប្រទេសនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរដែលបានជ្រើសរើស (ដុល្លារអាមេរិកក្នុងមួយខែ)

រូបភាព 5 ប្រៀបធៀបប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិខុសៗគ្នានៅទូទាំងប្រទេសនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរដែលបានជ្រើសរើសនៅក្នុងតំបន់អាស៊ី។ ការប្រៀបធៀបនេះ ផ្តល់នូវទស្សនៈចំពោះថ្លៃដើមកម្លាំងពលកម្មមូលដ្ឋាន និងការប្រកួតប្រជែងនៃប្រទេសនីមួយៗ[33]។

**រូបភាព 5៖ ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិនៃបណ្តាប្រទេសដែលបានជ្រើសរើសនៅតំបន់អាស៊ីក្នុងឆ្នាំ2022 (ដុល្លារអាមេរិកក្នុងមួយខែ)**




*ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិនៃសាធារណរដ្ឋប្រជាមានិតឡាវ នឹងចូលជាធរមានពីថ្ងៃទី1 ខែសីហា ឆ្នាំ2022។

សម្គាល់៖ ប្រទេសមួយចំនួនមានប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិលើសពីមួយ (អនុវត្តចំពោះតំបន់ភូមិសាស្ត្រផ្សេងៗគ្នា) ដែលក្នុងករណីនោះ អត្រាទាបបំផុត និងអត្រាខ្ពស់បំផុត គឺមានបង្ហាញនៅក្នុងតារាងជាពណ៌បៃតង។

ប្រភព៖ www.aseanbriefing.com, wageindicator.org, Dezan Shira & Associates (អត្ថបទសង្ខេបអំពីវៀតណាម , អត្ថបទសង្ខេបអំពីចិន ) និងអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេស។



ភាពញឹកញាប់នៃការកំណត់ប្រាក់ឈ្នួលអប្បបរមា មានភាពខុសគ្នាតាមប្រទេសនីមួយៗ។ មិនមានប្រការតាមបទប្បញ្ញត្តិដែលចែងអំពីភាពញឹកញាប់នៃការត្រួតពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមារបស់កម្ពុជានោះទេ ប៉ុន្តែ ទោះបីជាមានបញ្ញត្តិចែងក៏ដោយ ក៏ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិ ត្រូវបានត្រួតពិនិត្យឡើងវិញ និងបង្កើនជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ2013 មកនៅក្នុងប្រទេសកម្ពុជា មកទល់បច្ចុប្បន្នគឺអស់រយៈពេល 10 ឆ្នាំជាប់គ្នាហើយ។ បណ្តាប្រទេសផ្សេងទៀតនៅក្នុងតំបន់ មានបទប្បញ្ញត្តិក្នុងការត្រួតពិនិត្យឡើងវិញទៅលើប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិយ៉ាងតិចមួយឆ្នាំម្តង (វៀតណាម) រៀងរាល់ពីរឆ្នាំម្តង (មីយ៉ាន់ម៉ា ឬម៉ាឡេស៊ី) និងរៀងរាល់ប្រាំឆ្នាំ (បង់ក្លាដែស)។ ការរាតត្បាតជាសកលនៃជំងឺកូវីដ-19 បាននាំឱ្យមានការលើកលែងចំពោះវដ្តនៃការត្រួពិនិត្យឡើងវិញទាំងនេះនៅក្នុងបណ្តាប្រទេសជាក់លាក់មួយចំនួន។

នៅឆ្នាំ2021 ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិប្រចាំខែរបស់កម្ពុជា ត្រូវបានកំណត់យក US$ 194។ បច្ចុប្បន្ន ប្រាក់ឈ្នួលនេះ គឺអនុវត្តចំពោះតែវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរប៉ុណ្ណោះ។ ប្រសិនបើធៀបទៅនឹងគូប្រជែងនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិរបស់កម្ពុជា គឺមានកម្រិតខ្ពស់ជាងប្រាក់ឈ្នួលនៅមីយ៉ាន់មា សាធារណរដ្ឋប្រជាមានិតឡាវ ក៏ចជាតំបន់ជាក់លាក់នៃប្រទេសវៀតណាម និងឥណ្ឌូនេស៊ីផងដែរ។ ការត្រួតពិនិត្យឡើងវិញលើប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិរបស់កម្ពុជា សម្រាបឆ្នាំ2023 បច្ចុប្បន្នគឺកំពុងតែអនុវត្ត។ គ្រោងពេលវេលាសម្រាប់កិច្ចពិភាក្សានេះ គឺចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ2022 ហើយនៅដើមខែតុលា រដ្ឋាភិបាលបានយល់ព្រមដំឡើងប្រាក់ឈ្នួលអប្បបរមា ដល់ US$ 200 ក្នុងមួយខែ (ពី US$ 194)។ ប្រាក់ឈ្នួលដែលបានព្រមព្រៀងថ្មីនេះ នឹងត្រូវអនុវត្តពីថ្ងៃទី1 ខែមករា ឆ្នាំ2023។[34]

## ៥. លក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា

ទោះបីជាមានភស្តុតាងបញ្ជាក់ថា ការអភិវឌ្ឍឧស្សាហកម្មនាំចេញ ដូចជា ឧស្សាហកម្មកាត់ដេរជាដើម អាចចូលរួមចំណែកដល់កំណត់សេដ្ឋកិច្ចក៏ដោយ ក៏សក្តានុពលនៃឧស្សាហកម្មនេះក្នុងការផ្តល់នូវលទ្ធផលសង្គមប្រកបដោយភាពវិជ្ជមាន នៅតែពឹងផ្អែកទៅលើគុណភាពការងារ និងតថភាពនៃលក្ខខណ្ឌការងារនៅតាមកន្លែងធ្វើការនីមួយៗ។ ឧស្សាហកម្មនេះទាំងមូល ក៏គួរតែមានភាពធន់គ្រប់គ្រាន់ក្នុងការទប់ទល់នឹងឥទ្ធិពលនានា។ ការរាតត្បាតជាសកលនៃជំងឺកូវីដ-19 និងការបង្អាក់ការផ្គត់ផ្គង់ និងតម្រូវការពាក់ព័ន្ធ បានបង្ហាញអំពីលក្ខខណ្ឌទទេនៃ កង្វះភាពធន់ពេញលេញនៅក្នុងវិស័យ (មិនត្រឹមតែនៅកម្ពុជាប៉ុណ្ណោះទេ) ដើម្បីធានាថាវិស័យនេះជាយានសម្រាប់ការងារល្អប្រសើរ និងការអភិវឌ្ឍប្រកបដោយចីរភាព។[35]

កំណើននៃវិស័យកាត់ដេរនាំចេញនៅក្នុងប្រទេសកម្ពុជា គឺត្រូវបានជំរុញតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ឆ្នាំ1999 ប្រកបដោយភាពច្នៃប្រឌិតរវាងកម្ពុជា និងសហរដ្ឋអាមេរិក ដែលកំណត់លក្ខខណ្ឌការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដោយឈរលើលក្ខខណ្ឌកែលម្អលក្ខខណ្ឌការងារនៃវិស័យនេះ។ អង្គការពលកម្មអន្តរជាតិ រួមជាមួយនឹងរដ្ឋាភិបាលកម្ពុជា និងរោងចក្រកាត់ដេរកម្ពុជា បានដាក់ចេញនូវគំនិតផ្តួចផ្តើមតាមដានត្រួតពិនិត្យ ដើម្បីតាមដានការកែលម្អនេះ ដែលបានក្លាយជាគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់អង្គការពលកម្មអន្តរជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (ILO-IFC)។ គំនិតផ្តួចផ្តើមនេះ បន្តបម្រើ[36] ដល់តួនាទីដ៏សំខាន់មួយនៅក្នុងការគូសបង្ហាញឱ្យឃើញនូវការកែលម្អការងារបានល្អប្រសើរ និងឱនភាពនៅក្នុងវិស័យ ព្រមទាំងសម្របសម្រួលកិច្ចសន្ទនា និងការរៀបចំផែនការជាយុទ្ធសាស្ត្រក្នុងចំណោមភាគីពាក់ព័ន្ធរបស់វិស័យ ដែលតំណាងឱ្យរដ្ឋាភិបាល សមាគមកម្មករនិយោជិត និងសមាគមនិយោជក។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា មានការចូលរួមពីក្រុមហ៊ុននីមួយៗនៅក្នុងវិស័យ តាមរយៈការវាយតម្លៃអនុលោមភាពប្រចាំឆ្នាំ ដោយផ្អែកលើនីតិកម្មជាតិ និងបទដ្ឋានពលកម្មអន្តរជាតិ។ គ្រប់រោងចក្រកាត់ដេរ និងផលិតផលធ្វើដំណើរទាំងអស់ ទទួលបានការវាយតម្លៃដែលមិនបានប្រកាសនេះ ដោយមាននូវការវាយតម្លៃរងដែលជ្រើសរើសក្នុងការទទួលបានបន្សំនៃការបណ្តុះបណ្តាលឯកទេស និងសេវាពិគ្រោះយោបល់។ របាយការណ៍កម្មវិធីអំពីលទ្ធផលរកឃើញពីការវាយតម្លៃអនុលោមភាព គឺកំពុងបូកសរុប។ តួអង្គនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ដូចជាម៉ាកសម្លៀកបំពាក់ អាចចូលមើលរបាយការណ៍រោងចក្រនីមួយៗបានដោយឥតគិតថ្លៃ។ គម្រោងរោងចក្រកាន់តែប្រសើរ ក៏រាយការណ៍ជាសាធារណៈផងដែរអំពីលទ្ធផលអនុលោមភាព នៅកម្រិតក្រុមហ៊ុនទៅលើបញ្ហានៃអនុលោមភាព។

ទិន្នន័យថ្មីបំផុត និងគ្រប់ជ្រុងជ្រោយដែលមានសម្រាប់វាយតម្លៃលក្ខខណ្ឌការងារដែលកំពុងបូកសរុបនៅកម្ពុជា បានមកពីឆ្នាំរហូតមកដល់ការរាតត្បាតជាសកលនៃជំងឺកូវីដ-19។ ពេលវេលានេះគឺជាពេលវេលាមួយដែលការអាក់ខាននៅក្នុងវិស័យបានបង្ខំឱ្យកម្មវិធីងាកចេញពីគំរូស្តង់ដារនៃការវាយតម្លៃ។ ទិន្នន័យនេះបង្ហាញអំពីរូបភាពខុសគ្នានៃស្ថានភាពបច្ចុប្បន្ននៃលក្ខខណ្ឌការងារនៅក្នុងវិស័យ។

ឧទាហរណ៍ ការមិនអនុលោមតាមការទូទាត់ប្រាក់ឈ្នួលអប្បបរមាដូចដែលបានតម្រូវដោយច្បាប់ (ក្នុងចំណោមរោងចក្រចំនួន 404 ដែលបានវាយតម្លៃ) នៅក្នុងរយៈពេលនោះ គឺមាន 21%។ ទោះបីជាមានក្រុមហ៊ុនមួយក្នុងចំណោមប្រាំក្រុមហ៊ុន រកឃើញថាមិនអនុលោមតាមបទប្បញ្ញត្តិទាំងនេះក៏ដោយ ក៏តួលេខនេះបង្ហាញឱ្យឃើញអំពីការកែលម្អយ៉ាងខ្លាំងពីរយៈពេលវាយតម្លៃពីមុន។ នៅក្នុងកម្រងម៉ោងការងារ ស្របពេលមានក្រុមហ៊ុនតែ 23% ប៉ុណ្ណោះដែលមិនអនុលោមតាមម៉ោងទៀងទាត់ ក្រុមហ៊ុនចំនួន 77% គឺមិនអនុលោមតាមទិដ្ឋភាពមួយចំនួននៃបទប្បញ្ញត្តិអំពីការងារបន្ថែមម៉ោង។[37]

ការមិនអនុលោមតាមនៅក្នុងផ្នែកភាគច្រើននៃបទដ្ឋានពលកម្មស្នូលរបស់អង្គការពលកម្មអន្តរជាតិ - ពលកម្មកុមារ ការរើសអើងពលកម្មដោយបង្ខំ និងសេរីភាពខាងសមាគម/ការចរចាសមូហភាព - គឺត្រូវបានរកឃើញជាប់ៗគ្នាថាមានកម្រិតទាប ប៉ុន្តែបញ្ហាទាំងនេះក៏អាចមានលក្ខណៈកាន់តែលំបាកសម្រាប់បុគ្គលិកគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាក្នុងការស្វែងរក។

គិតត្រឹមឆ្នាំ2022 បទដ្ឋានពលកម្មស្នូលទីប្រាំថ្មីរបស់អង្គការពលកម្មអន្តរជាតិ គ្របដណ្ដប់លើសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ (OSH)។ ស្ទើរតែជិតមួយភាគបួននៃសំណួរអំពីឧបករណ៍វាយតម្លៃអនុលោមភាពរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺផ្ដោតលើសុវត្ថិភាព និងសុខភាពការងារ ហើយទិន្នន័យចុងក្រោយដែលមាននៅទូទាំងវិស័យ បង្ហាញអំពីបញ្ហាប្រឈមដែលកំពុងកើតមានចំពោះការសម្រេចឱ្យបានអនុលោមភាពតាមបទប្បញ្ញត្តិជាតិ ដែលមានចាប់ពីការត្រៀមរៀបចំពេលមានអាសន្ន (ក្រុមហ៊ុន 68% មិនអនុលោមតាម) រហូតដល់សេវាសុខភាព និងការសង្គ្រោះបឋម (ក្រុមហ៊ុន 92% មិនអនុលោមតាម)។[38]

លើសពីនេះ លក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរនៅកម្ពុជា គឺត្រូវបានសិក្សាជាញឹកញាប់ដោយអ្នកស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិផងដែរ។[39] គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា លើកទឹកចិត្ត និងសម្របសម្រួលការស្រាវជ្រាវឯករាជ្យទៅលើស្ថានភាពនៃឧស្សាហកម្មនេះ និងលក្ខខណ្ឌការងារនៅក្នុងវិស័យនេះ។ ការស្រាវជ្រាវនេះ បានចូលរួមចំណែកដល់ការបំពេញចំណេះដឹងអំពីការងារដែលត្រូវលើកទឹកចិត្តឱ្យមានការកែលម្អទៅលើលក្ខខណ្ឌការងារ ក៏ដូចជាបញ្ហាប្រឈមដែលមិនទាន់បានដោះស្រាយផងដែរ។ ក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយម៉ាកអន្តរជាតិដែលមានកេរ្តិ៍ឈ្មោះល្បី គឺទំនងជាមានលក្ខខណ្ឌការងារល្អប្រសើរ ហើយក្រុមហ៊ុនដែលបានប្តេជ្ញាចិត្តក្នុងការកែលម្អលក្ខខណ្ឌការងារ គឺទំនងជាអាចបន្តរួចផុតពីឥទ្ធិពលអវិជ្ជមាននៃសេដ្ឋកិច្ច។ ដំណើរការនៃការរាយការណ៍អំពីលទ្ធផលវាយតម្លៃអនុលោមភាពជាសាធារណៈ ក៏ទំនងជាជំរុញដល់ការកែលម្អជាបន្តបន្ទាប់នៅក្នុងក្រុមហ៊ុន ហើយការអន្តរាគមន៍ទាំងមូលរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺមានលក្ខណៈគាំទ្រដល់ការលើកកម្ពស់ផលិតភាពនៅកន្លែងការងារផងដែរ។

ការស្រាវជ្រាវឯកទេស ក៏អាចរកឃើញបញ្ហាប្រឈមនានាសម្រាប់កម្មករនិយោជិតដែលការវាយតម្លៃអនុលោមភាពធម្មតាមិនអាចរកឃើញ។ ឧទាហរណ៍ ការបៀតបៀនផ្លូវភេទ គឺជាបញ្ហាមួយដែលពិបាកក្នុងការរកឃើញបំផុតពីការវាយតម្លៃអនុលោមភាព ប៉ុន្តែបានរាយការណ៍យ៉ាងជាប់លាប់នៅក្នុងការស្រាវជ្រាវក្នុងចំណោមកម្មករនិយោជិត។ ការបណ្ដុះបណ្ដាល និងការប្រឹក្សាយោបល់របស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាទៅលើប្រធានបទនានា ក៏ដូចជាសេវាប្រឹក្សាយោបល់នានា ក៏ធ្វើឱ្យប្រាកដថា ប្រព័ន្ធគ្រប់គ្រងប្រាក់ឈ្នួល គឺមានភាពយុត្តិធម៌ និងតម្លាភាព ដែលអាចជួយដោះស្រាយបញ្ហានៅក្នុងវិស័យនេះបាន។[40] ការស្រាវជ្រាវផ្សេងៗបង្ហាញឱ្យឃើញអំពីការលំបាកជាបន្តបន្ទាប់ចំពោះកម្មករនិយោជិតក្នុងអំឡុងពេល និងក្រោយពេលការរាតត្បាតជាសកលនៃជំងឺកូវីដ-19 នៅពេលដែលអសន្តិសុខការងារ កង្វះការគាំពារសង្គមពេញលេញ និងជីវភាពងាយរងគ្រោះ គឺត្រូវបាណបង្ហាញឱ្យឃើញ និងផ្សារភ្ជាប់ទៅនឹងគំរូអាជីវកម្មនៅតាមខ្សែប្រវាក់ផ្គត់ផ្គង់នៃវិស័យកាត់ដេរសកល។[41]



## ៦. វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរក្នុងអំឡុងពេលនៃជំងឺកូវីដ-19 និងការគាំទ្រដែលទទួលបានពីរដ្ឋាភិបាល

សេដ្ឋកិច្ចកម្ពុជា បានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងឆ្នាំ2020 និង 2021។ ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ជាប់គាំង 3.1% នៅឆ្នាំ2020 (ការធ្លាក់ចុះក្នុងរយៈពេល 27 ឆ្នាំមកនេះ) ដោយសារតែសេដ្ឋកិច្ចទទួលរងផលប៉ះពាល់ពីបញ្ហាការផ្គត់ផ្គង់ និងតម្រូវការបណ្ដាលមកពីជំងឺរាតត្បាតជាសកល។ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ បានធ្លាក់ចុះ 10% នៅឆ្នាំ2020 (ធៀបទៅនឹងឆ្នាំ2019)។

ជាបន្តបន្ទាប់ ស្របពេលដែលមានលទ្ធភាពគ្រប់គ្រងជំងឺកូវីដ-19 បានកាន់តែល្អប្រសើរជាងមុន ដោយសារតែកម្មវិធីចាក់ថ្នាំបង្ការដ៏ជោគជ័យកម្រិតខ្ពស់ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្ដើមស្ដារឡើងវិញ ដោយទទួលបានកំណើនផលិតផលក្នុងស្រុកសរុប 3% នៅឆ្នាំ2021។ ផ្ទុយទៅនឹងបណ្ដាប្រទេសផលិតកម្មសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរភាគច្រើន កម្ពុជាមិនដែលបិទរោងចក្ររបស់ខ្លួនទាំងស្រុងស្របពេលជាមួយគ្នានោះទេ ដែលទំនងជាចូលរួមចំណែកដល់ការប៉ះពាល់កម្រិតទាបបង្កឡើងដោយការរាតត្បាតនៃជំងឺនេះ បើធៀបទៅនឹងបណ្ដាប្រទេសផលិតកម្មផ្សេងទៀត។

កម្ពុជាបច្ចុប្បន្ន (ខែតុលា ឆ្នាំ2022) គឺជាប់ចំណាត់ថ្នាក់លេខ 4 ក្នុងចំណោមប្រទេសចំនួន 121 ប្រទេសនៅក្នុងសន្ទស្សន៍ Nikkei ស្ដីពីការស្ដារប្រទេសឡើងវិញពីជំងឺកូវីដ-19 ដោយឆ្លុះបញ្ចាំងឱ្យឃើញអំពីសមត្ថភាពរបស់ប្រទេសក្នុងការគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ-19។ ស្ថិតិផ្លូវការពីក្រសួងពាណិជ្ជកម្ម (MoC) ពិតជាបានបង្ហាញឱ្យឃើញថា ទោះជាយ៉ាងនេះក្ដី វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ បន្សល់នូវស្លាកស្នាមមួយចំនួន។ ការបិទ ឬផ្អាករោងចក្រចំនួន 134 រោងចក្រ គឺត្រូវបានកើតឡើង ដោយមានកម្មករនិយោជិតស្ទើរតែជិត 45,000 នាក់បានបាត់បង់ការងារនៅចន្លោះឆ្នាំ2020 និង 2021។[43] កម្មករនិយោជិតភាគច្រើននៃកម្មករនិយោជិតទាំងនេះ គឺជាស្ត្រី នេះបើយោងតាមការវិភាគយេនឌ័ររហ័សដោយអង្គការ ឃែរកម្ពុជា ដែលជាអ្នកទទួលរងផលប៉ះពាល់មិនស្មើភាពគ្នាដោយសារតែជំងឺកូវីដ-19។ បញ្ហាធំបំផុតដែលស្ត្រីទាំងនេះបានជួបប្រទះនោះគឺ i) កង្វះប្រាក់ចំណូល/បាត់បង់ការងារ និង ii) បញ្ហាថប់អារម្មណ៍ និងសម្ពាធផ្លូវចិត្តកើនឡើង។[44]

រដ្ឋាភិបាលកម្ពុជា បានចាត់វិធានការដើម្បីគាំទ្រដល់វិស័យ នេះ និងកម្មករនិយោជិតដែលរងផលប៉ះពាល់។ និយោជកបានទទួល៖

i. រយៈពេលលើកលែងពន្ធ (ពីពន្ធលើប្រាក់ចំណូលសាជីវកម្ម)។
ii. ការលើកលែងពីការទូទាត់ភាគទានជាតិសន្តិសុខសង្គម (ការគ្របដណ្ដប់លើសេវាថែទាំសុខភាពកម្មករនិយោជិត ជំងឺ/របួសពាក់ព័ន្ធនឹងការងារ និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងការធ្វើដំណើរ) ជូនដល់បេឡាជាតិរបបសន្តិសុខសង្គម (បសស)[45]។
iii. ការកាត់បន្ថយពន្ធលើអគ្គិសនីសម្រាប់ឧស្សាហកម្ម/ក្រុមហ៊ុននៅក្នុងវិស័យចំនួនបួន - ផលិត កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម (ខែមិថុនា ដល់ខែតុលា ឆ្នាំ2020)។

កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ បានទទួលការគាំទ្រជាក់លាក់ដូចជា៖

i. គម្រោងគាំទ្រហិរញ្ញវត្ថុរបស់រដ្ឋាភិបាល (ចែកសាច់ប្រាក់) ដែលគម្រោងនេះគឺទូទាត់ជូនកម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដោយផ្អែកលើចំនួនថ្ងៃធ្វើការដែលបានផ្អាក។ 61,500 រៀល (ប្រមាណជា US$ 15.5) ត្រូវបានទូទាត់ជូនកម្មករនិយោជិតដែលត្រូវបានផ្អាកកិច្ចសន្យាសម្រាប់រយៈពេល 7 ទៅ 10 ថ្ងៃ 123,000 រៀល (ប្រមាណជា US$ 30.5) សម្រាប់អ្នកដែលបានផ្អាកពី 11 ទៅ 20 ថ្ងៃ និង 164,000 រៀល (ប្រមាណជា US$ 41) សម្រាប់អ្នកដែលបានផ្អាកពី 21 ថ្ងៃដល់មួយខែ។ កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ចំនួន 329,541 នាក់ បានទទួលអត្ថប្រយោជន៍ពីគម្រោងនេះក្នុងរយៈពេលពីរឆ្នាំនៃការអនុវត្តគម្រោងនេះ (ខែមិថុនា ឆ្នាំ2020 - ខែមិថុនា ឆ្នាំ2022)។[46]
ii. កម្មវិធីគាំទ្រតាមរយៈការចែកប្រាក់របស់រដ្ឋាភិបាលសម្រាប់កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។ ការចែកប្រាក់នេះ គឺជាការទូទាត់តែមួយលើកនូវទឹកប្រាក់ចំនួន US$ 40 ដែលបានផ្ដល់ជនដល់កម្មករនិយោជិតដែលមិនអាចទៅធ្វើការបាន ដោយសារតែការបិទខ្ទប់របស់រដ្ឋាភិបាល។ ការគាំទ្រនេះ ត្រូវបានផ្ដល់ជូននៅក្នុងតំបន់មានអាសន្នកម្រិតខ្ពស់ចំនួនបីតំបន់ប៉ុណ្ណោះ មាន

ដូចជា (1) រាជធានីភ្នំពេញ (2) ក្រុងតាខ្មៅ ខេត្តកណ្តាល និង (3) ខេត្តព្រះសីហនុ។[47]

iii. ជំនួយសង្គមរបស់រដ្ឋាភិបាល។ កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលឆ្លងជំងឺកូវីដ-19 (ពីព្រឹត្តិការណ៍ 20 កុម្ភៈ 2021) បានទទួលការទូទាត់សាច់ប្រាក់តែមួយលើកចំនួន US$ 40 ក្នុងកម្មករនិយោជិតម្នាក់។ ជំនួយនេះ គឺសម្រាប់តែកម្មករនិយោជិតដែលរស់នៅក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងខេត្តព្រះសីហនុប៉ុណ្ណោះ។[48]

iv. ការគាំទ្រសម្រាប់គ្រួសារដែលមានអ្នកស្លាប់។ គ្រួសារនៃកម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ដែលបានស្លាប់ដោយសារជំងឺកូវីដ-19 (ក្នុងព្រឹត្តិការណ៍ 20 កុម្ភៈ 2021) បានទទួលការផ្តល់ជូនសាច់ប្រាក់តែមួយលើក និងជំនួយមិនមែនហិរញ្ញវត្ថុ ដែលស្មើនឹងទឹកប្រាក់ចន្លោះ US$ 110 និង US$ 190 អាស្រ័យលើទំហំគ្រួសារ។[49]

v. កម្មវិធីបណ្តុះបណ្តាលជំនាញទន់សម្រាប់និយោជិតដែលត្រូវបានផ្អាក (បញ្ឈប់ការងារបណ្តោះអាសន្ន)។ ការបណ្តុះបណ្តាលនេះ គឺត្រូវបានផ្តល់ជូនដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ដើម្បីបណ្តុះបណ្តាលឡើងវិញ និងបំប៉នជំនាញរបស់កម្មករនិយោជិតដែលបានផ្អាកការងារ។ កម្មករនិយោជិតដែលបានស្ម័គ្រចិត្តចុះឈ្មោះនៅក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញទន់ បានទទួលប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិចំនួន 20% បន្ថែម (ដែលស្មើនឹង US$ 38 ក្នុងកម្មករនិយោជិតម្នាក់ក្នុងមួយខែ)។ កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ចំនួន 68,000 នាក់ បានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ ក្នុងរយៈពេល 2 ឆ្នាំនៃការអនុវត្តគម្រោងនេះ (ខែមិថុនា ឆ្នាំ2020 - ខែមិថុនា ឆ្នាំ2022)។[50]

## ៧. ការបង្កើតគោលនយោបាយពាក់ព័ន្ធនឹងវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ

វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរកម្ពុជាបាន និងកំពុងស្ថិតក្រោមការបង្កើតគោលនយោបាយផ្សេងៗគ្នាជាច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ បញ្ជីខាងក្រោមនេះគ្រាន់តែបង្ហាញអំពីការអភិវឌ្ឍដែលមានឥទ្ធិពលបំផុតប៉ុណ្ណោះ ដូច្នេះគឺមិនមានលក្ខណៈលម្អិតនោះទេ៖

1. នៅថ្ងៃទី21 ខែមីនា ឆ្នាំ2022 កម្ពុជាបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ឆ្នាំ2022-2027" ដោយមានគោលបំណងបង្កើនសមត្ថភាពវិស័យនេះទៅជាឧស្សាហកម្មមួយដែលមានចីរភាព និងភាពធន់បរិស្ថាន ដែលមានគុណតម្លៃបន្ថែមកម្រិតខ្ពស់ និងផលិតផលពិសេសប្លែកពីគេ។ យុទ្ធសាស្ត្រនេះក៏មានគោលបំណងបង្កើនឯករាជ្យភាព ព្រមទាំងពង្រឹងលទ្ធភាពព្យាករណ៍ និងស្ថិរភាពរបស់វិស័យផងដែរ។ ដើម្បីសម្រេចបានតាមចក្ខុវិស័យនេះ កម្ពុជាមានបំណងអនុវត្តនូវវិធានការដូចខាងក្រោម៖

   a. ពង្រឹងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងបង្កើតវិថីអាជីពការងារសម្រាប់កម្មករ/និយោជិតកម្ពុជា
   b. បន្តកែលម្អលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ/និយោជិត
   c. លើកកម្ពស់ការវិនិយោគក្នុងស្រុក និងបរទេសនៅក្នុងឧស្សាហកម្ម ការផ្តោតលើផលិតផលគុណតម្លៃបន្ថែមកម្រិតខ្ពស់ គុណភាពកម្រិតខ្ពស់ និងពិសេស
   d. ទាក់ទាញការវិនិយោគទៅលើការគាំទ្រឧស្សាហកម្ម និង
   e. លើកកម្ពស់ពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ។[51]

ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យប្រកបដោយចីរភាព និងបរិយាប័ន្នបន្ថែមទៀត យុទ្ធសាស្ត្រនេះមានគោលបំណងរក្សា និងចាប់យកឱកាសទីផ្សារថ្មីៗ ទាំងនៅក្នុងទីផ្សារអនុគ្រោះមានស្រាប់ និងទីផ្សារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីៗ (FTAs)[52] ដូចដែលបានពន្យល់លម្អិតនៅក្នុងផ្នែក 2ខ។

2. នៅខែកញ្ញា ឆ្នាំ2022 កម្ពុជាបានបង្កើនដែនកំណត់ប្រាក់បៀវត្សប្រចាំខែ ដែលនឹងត្រូវស្ថិតក្រោមពន្ធលើប្រាក់បៀវត្សដល់ 1,500,001 រៀល (ប្រមាណជា US$ 375)[53] ដើម្បីបង្កើនកម្រិតជីវភាពរស់នៅរបស់កម្មករនិយោជិតដែលមានប្រាក់ចំណូលទាប ក៏ដូចជាមន្ត្រីរាជការរបស់រដ្ឋាភិបាលផងដែរ។ ប្រាក់ឧបត្ថម្ភ/អត្ថប្រយោជន៍មិនមែនប្រាក់ខែ (ដូចជាប្រាក់ឧបត្ថម្ភលើការធ្វើដំណើរ/ការស្នាក់នៅ ជាដើម) របស់កម្មករនិយោជិត គឺមិនរួមបញ្ចូលនៅក្នុងការគណនាពន្ធលើប្រាក់បៀវត្សរបស់ពួកគាត់នោះទេ។[54] កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរភាគច្រើន មិនចាំបាច់បង់ពន្ធលើប្រាក់ចំណូលទេ ដោយសារតែប្រាក់ឈ្នួលសុទ្ធប្រចាំខែជាមធ្យមរបស់ពួកគាត់ គឺត្រឹមតែ US$ 263 ប៉ុណ្ណោះ (ត្រីមាសទីមួយឆ្នាំ2022)។ លើសពីនេះ ដោយពិចារណាទៅលើប្រាក់ឈ្នួលអប្បបរមាថ្មីសម្រាប់ឆ្នាំ2023 និងអត្ថប្រយោជន៍ផ្សេងទៀត ដែនកំណត់ត្រូវបានដំឡើងបន្ថែមដល់ 1,500,001 រៀល (ប្រមាណជា US$ 375) គិតត្រឹមថ្ងៃទី22 ខែកញ្ញា ឆ្នាំ2022[55]។

3. ការអភិវឌ្ឍផ្សេងទៀតពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់កម្មករនិយោជិត (នៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ) រួមមាន៖[56]

   - ប្រាក់ឈ្នួលអប្បបរមាតាមបទប្បញ្ញត្តិមានការធានាដែលត្រូវទូទាត់ជូនកម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ៖ ការពិន័យ/ការផាកពិន័យចំពោះការមិនអនុលោមតាម។
   - កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរជាស្ត្រីដែលមានច្បាប់ឈប់សម្រាកមាតុភាព 90 ថ្ងៃ ទទួលបាន 120% នៃប្រាក់បៀវត្សប្រចាំខែរបស់ពួកគាត់ ដែលក្នុងចំនួនទឹកប្រាក់នោះ 70% គឺត្រូវទូទាត់ដោយបេឡាជាតិរបបសន្តិសុខសង្គម (បសស) និង 50% គឺត្រូវទូទាត់ដោយនិយោជករបស់ពួកគាត់។ អត្ថប្រយោជន៍នេះគឺអនុវត្តចំពោះកម្មករនិយោជិតដែលចុះឈ្មោះនៅបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះ។[57]
   - ប្រាក់រង្វាន់អតីតភាពការងាររបស់កម្មករនិយោជិត នឹងត្រូវទូទាត់រៀងរាល់ 6 ខែម្តង។

4. មានប្រសិទ្ធភាពពីថ្ងៃទី01 ខែមករា ឆ្នាំ2018 កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរជាស្ត្រី ទទួលបានការគាំទ្រពីរដ្ឋាភិបាលចំនួន 400,000 រៀល (ប្រមាណជា US$ 100) នៅពេលសម្រាលកូនទោល 800,000 រៀល (ប្រមាណជា US$ 200) សម្រាប់កូនភ្លោះ និង 1,200,000 រៀល (ប្រមាណជា US$ 300) សម្រាប់កូនភ្លោះបី។

5. នៅថ្ងៃទី27 ខែឧសភា ឆ្នាំ2022 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញលិខិតបង្គាប់ជូនដល់[58] ម្ចាស់ និងអ្នកគ្រប់គ្រងរោងចក្រកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរទាំងអស់នៅកម្ពុជា តម្រូវឱ្យម្ចាស់ និងអ្នកគ្រប់គ្រងអនុលោមតាមលក្ខខណ្ឌតម្រូវចំនួន 31 នៅក្នុងផ្នែកចម្បងៗចំនួនប្រាំ មានដូចជា ក) បែបបទនៃវិធាន និងបទប្បញ្ញត្តិរបស់សហគ្រាស (ការផ្សព្វផ្សាយទូលំទូលាយ និងបើកចំហជាដើម) ខ) លក្ខខណ្ឌការងារ (ការទូទាត់ត្រឹមត្រូវនៃប្រាក់ឈ្នួលអប្បបរមា និងការងារថែមម៉ោងដែលបានអនុម័ត លក្ខខណ្ឌការងារ/ច្បាប់ការងារជាដើម) គ) លក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារ (អនាម័យ ប្រព័ន្ធខ្យល់ចេញចូល បរិក្ខារសង្គ្រោះបឋមជាដើម) ឃ) លក្ខខណ្ឌនៃគម្រោងសន្តិសុខសង្គម (ការចុះឈ្មោះ និងការទូទាត់នៃហានិភ័យការងារ និងគម្រោងថែទាំសុខភាពរបស់បេឡាជាតិរបបសន្តិសុខសង្គមជាដើម) ង) លក្ខខណ្ឌទំនាក់ទំនងឧស្សាហកម្ម (ពាក់ព័ន្ធនឹងសហភាពពាណិជ្ជកម្ម/សហជីព វិវាទការងារជាដើម)។ បេឡាជាតិរបបសន្តិសុខសង្គម ជាគម្រោងធានារ៉ាប់រងប្រតិបត្តិការដោយរដ្ឋាភិបាលនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កន្លងមកបានដាក់ចេញនូវគម្រោងសន្តិសុខសង្គមចំនួនបី ដែលអនុវត្តចំពោះអ្នកដែលធ្វើការងារ/ធ្វើប្រតិបត្តិការនៅក្រោមបញ្ញត្តិនៃច្បាប់ការងាររបស់កម្ពុជា (រួមទាំង កម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ)។ **គម្រោងសន្តិសុខសង្គមទី 1** ដែលគ្របដណ្តប់លើរបួសរបស់កម្មករនិយោជិត ជំងឺពាក់ព័ន្ធនឹងការងារ និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងការធ្វើដំណើរបានអនុវត្តនៅពាក់កណ្តាលឆ្នាំ2008 **គម្រោងសន្តិសុខសង្គមទី 2** ដែលគ្របដណ្តប់លើសេវាថែទាំសុខភាព[59] របស់កម្មករនិយោជិត ត្រូវបានអនុវត្តនៅខែឧសភា ឆ្នាំ2016 និង **គម្រោងសន្តិសុខសង្គមទី 3** ដែលគ្របដណ្តប់សោធនរបស់កម្មករនិយោជិត ត្រូវបានដាក់ដំណើរការនៅខែកក្កដា ឆ្នាំ2022 ជាមួយនឹងភាគទានហិរញ្ញវត្ថុជាក់ស្តែងពីនិយោជក និងកម្មករនិយោជិត ចាប់ផ្តើមពីថ្ងៃទី1 ខែតុលា ឆ្នាំ2022។[60] យោងតាមអនុក្រឹត្យរបស់រដ្ឋាភិបាល (លេខ 32 ដែលបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី4 ខែមីនា ឆ្នាំ2021) គម្រោងសោធន នឹងត្រូវអនុវត្តចំពោះបុគ្គលទាំងអស់ដែលធ្វើការងារ និងធ្វើប្រតិបត្តិការនៅក្រោមបញ្ញត្តិនៃច្បាប់ការងាររបស់កម្ពុជា ដែលរួមបញ្ចូលនិយោជិត/កម្មករនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ។ ក្នុងរយៈពេលប្រាំឆ្នាំដំបូងនៃការអនុវត្ត (ដំណាក់កាលទី 1) អត្រាភាគទានហិរញ្ញវត្ថុចំពោះគម្រោង

នេះគឺ 4% នៃប្រាក់ឈ្នួលដុលរបស់និយោជិត (ដែលបែងចែកស្មើគ្នារវាងនិយោជក និងកម្មករនិយោជិត)។ បន្ទាប់ពីការអនុវត្តដំណាក់កាលទីមួយបានបញ្ចប់ អត្រាភាគទានហិរញ្ញវត្ថុចំពោះគម្រោង នឹងដំឡើងទៅ 8% នៃប្រាក់ឈ្នួលដុលរបស់និយោជិត (ដំណាក់កាលទី 2) ដែលនឹងអនុវត្តសម្រាប់រយៈពេល 5 ឆ្នាំទៀត។[61]

**ការពិនិត្យស៊ីជម្រៅ៖ វិស័យផលិតផលធ្វើដំណើរ (TG) នៅកម្ពុជា**

នៅក្នុងរយៈពេលគ្រាន់តែមួយសតវត្សប៉ុណ្ណោះ ការនាំចេញទំនិញនៃវិស័យផលិតផលធ្វើដំណើររបស់កម្ពុជា បានហក់ឡើងពីត្រឹមតែ 10.5 លានដុល្លារអាមេរិក[62] នៅឆ្នាំ2012 ដល់ 1,495 លានដុល្លារអាមេរិកនៅឆ្នាំ2021។[63] កម្ពុជា បានចាប់ផ្តើមពីការមិនសូវមានគេស្គាល់នៅលើទីផ្សារផលិតផលធ្វើដំណើរពិភពលោក (ចំណែកនាំចេញ 0.02% នៅឆ្នាំ2012) រហូតដល់បច្ចុប្បន្ននេះជាប់ចំណាត់ថ្នាក់លេខ 6 ក្នុងចំណោមប្រទេសនាំចេញកំពូលៗ (ចំណែក 1.6% នៅឆ្នាំ2021)។ បច្ចុប្បន្ននេះ កម្ពុជាគឺជាប្រទេសនាំចេញមួយក្នុងចំណោមប្រទេសនាំចេញផលិតផលធ្វើដំណើរនាំមុខគេក្នុងចំណោមបណ្តាប្រទេសនៅក្នុងអាស៊ាន (តារាង 4)។ ដោយទទួលស្គាល់សក្តានុពលរបស់ខ្លួន នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរឆ្នាំ2022-2027 រដ្ឋាភិបាលកម្ពុជាបានគូសបញ្ជាក់អំពីផលិតផលធ្វើដំណើរអាទិភាពដែលចូលរួមចំណែកយ៉ាងសំខាន់ចំពោះការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

**តារាង 4. ប្រទេសនាំចេញផលិតផលធ្វើដំណើរកំពូលទាំង 15 ក្នុងនាមជាចំណែកនៃទីផ្សារផលិតផលធ្វើដំណើរពិភពលោក** (គិតជាភាគរយ) – កម្ពុជាឈរនោះលំដាប់លេខ 6 នៅឆ្នាំ2021

| | 1995 | 2005 | 2015 | 2018 | 2019 | 2020 | 2021 |
|---|---|---|---|---|---|---|---|
| ប្រទេសនាំចេញផលិតផលធ្វើដំណើរ | 63.9 | 59.9 | 65.6 | 59.2 | 57.7 | 55.3 | 56.9 |
| 1. ចិន | 19.2 | 31.1 | 46.6 | 40.1 | 37.6 | 35.2 | 37.2 |
| 2. វៀតណាម | 0.7 | 1.3 | 4.2 | 4.3 | 4.5 | 4.4 | 5.2 |
| 3. ហុងកុង តំបន់រដ្ឋបាលពិសេស ចិន | 31.0 | 20.3 | 7.8 | 6.0 | 5.5 | 5.6 | 4.5 |
| 4. ឥណ្ឌា | 2.1 | 2.2 | 2.0 | 2.1 | 2.0 | 1.8 | 1.8 |
| 5. សិង្ហបុរី | 0.4 | 0.7 | 0.9 | 1.4 | 1.4 | 1.5 | 1.7 |
| 6. កម្ពុជា | **0.0** | **0.0** | **0.2** | **0.8** | **1.3** | **1.8** | **1.6** |
| 7. ឥណ្ឌូនេស៊ី | 0.6 | 0.3 | 0.4 | 0.7 | 0.9 | 1.0 | 0.9 |
| 8. ហ្វីលីពីន | 0.7 | 0.3 | 0.7 | 0.8 | 1.0 | 0.7 | 0.9 |
| 9. ថៃ | 3.0 | 0.9 | 0.5 | 0.5 | 0.6 | 0.4 | 0.5 |
| 10. U.A.E | 0.1 | 0.3 | 0.3 | 0.4 | 0.4 | 0.4 | 0.4 |
| 11. មីយ៉ាន់ម៉ា | 0.0 | 0.0 | 0.0 | 0.2 | 0.5 | 0.6 | 0.4 |
| 12. ទួគី | 0.2 | 0.3 | 0.3 | 0.3 | 0.3 | 0.3 | 0.3 |
| 13. មិកស៊ិក | 0.6 | 0.3 | 0.3 | 0.2 | 0.3 | 0.3 | 0.3 |
| 14. បង់ក្លាដែស | 0.0 | 0.0 | 0.3 | 0.3 | 0.3 | 0.2 | 0.3 |
| 15. តៃវ៉ាន់ ចិន | 3.0 | 0.2 | 0.2 | 0.2 | 0.2 | 0.2 | 0.2 |
| ផ្សេងៗ | **36.1** | **40.1** | **34.4** | **40.8** | **42.3** | **44.7** | **43.1** |
| ពិភពលោក | **100** | **100** | **100** | **100** | **100** | **100** | **100** |

*ប្រភព៖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) (បានចូលមើលនៅថ្ងៃទី16 ខែកក្កដា ឆ្នាំ2022)។ ចំណែកភាគរយ គឺត្រូវបានគណនាដោយផ្អែកលើតម្លៃនាំចេញរបស់ប្រទេស។*

សម្គាល់៖ U.A.E សម្តៅទៅលើអារ៉ាប់រួម

កំណើនយ៉ាងរហ័សនៃវិស័យផលិតផលធ្វើដំណើរ បង្កើតឡើងយ៉ាងធំពីសេចក្តីសម្រេចរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីពង្រីកប្រព័ន្ធអនុគ្រោះទូទៅ (GSP)។ ការពង្រីកប្រព័ន្ធអនុគ្រោះទូទៅដែលបានចូលជាធរមាននៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2016 និងផ្តល់ជូនដល់កម្ពុជា ក្នុងចំណោមបណ្តាប្រទេសផ្សេងទៀត នូវការនាំចេញមិនគិតពន្ធគយនៃផលិតផលធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក។ ដូច្នេះ មានការគួរឱ្យភ្ញាក់ផ្អើលបន្តិចដែរ ដែលចំណែកនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមានការកើនឡើងជាលំដាប់។ ស្ថិតិផ្លូវការពីអគ្គនាយកដ្ឋានគយ និងរដ្ឋាកររបស់កម្ពុជា បង្ហាញថា នៅឆ្នាំ2021 ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជា 80% គឺដឹកជញ្ជូនទៅកាន់សហរដ្ឋអាមេរិក ធៀបនឹងការនាំចេញត្រឹម 20% ប៉ុណ្ណោះនៅឆ្នាំ2012។ កំណើននេះស្មើនឹងអត្រាកំណើនជាមធ្យម 102% ក្នុងមួយឆ្នាំទៅកាន់សហរដ្ឋអាមេរិកក្នុងរយៈពេលពីឆ្នាំ2017-2021។ ទន្ទឹមនឹងនេះ ការនាំចេញផលិតផលធ្វើដំណើរតែ 6% ប៉ុណ្ណោះដែលត្រូវបាននាំចេញទៅកាន់សហភាពអឺរ៉ុបនៅឆ្នាំ2021 ដោយការនាំចេញនៅសល់ 14% គឺត្រូវបាននាំចេញទៅកាន់ទៅផ្សារផ្សេងទៀត (តារាង 5)។

ដោយសារតែចំណែកនាំចេញទាបនៃផលិតផលធ្វើដំណើរកម្ពុជាទៅកាន់សហភាពអឺរ៉ុប ការដកចេញដោយផ្នែកនៃគំនិតផ្តួចផ្តើមអនុគ្រោះអ្វីគ្រប់យ៉ាង លើកលែងតែអាវុធរបស់សហភាពអឺរ៉ុបនៅឆ្នាំ2020[64] មានផលប៉ះពាល់តិចតួចទៅលើវិស័យផលិតផលធ្វើដំណើរទាំងមូល។ ប៉ុន្តែ ការដកចេញនេះពិតជាបានធ្វើឱ្យមានការថយចុះនៃចំណែករបស់ផលិតផលធ្វើដំណើររបស់កម្ពុជាដែលមានទិសដៅនាំចេញទៅកាន់សហភាពអឺរ៉ុប។ ដោយមាននូវផ្នែកពន្ធផលិតផលចំនួន 5 ផ្នែកដែលបានរងផលប៉ះពាល់ពីការដកចេញដោយផ្នែកនៃប្រព័ន្ធអនុគ្រោះ សហភាពអឺរ៉ុបចាប់ផ្តើមពីទិសដៅ 12% នៃការនាំចេញផលិតផលធ្វើដំណើរការរបស់កម្ពុជានៅឆ្នាំ2019 ទៅជាត្រឹម 6% នៅឆ្នាំ2021 (ឬ 7% នៅពេលរួមបញ្ចូលចក្រភពអង់គ្លេស)។

**តារាង 5៖ ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជា** (គិតជាលានដុល្លារអាមេរិក) **កំណើន** (គិតជាភាគរយ) **និងសមាសភាគចំណែកទីផ្សារ** (គិតជាភាគរយ)

| ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជា (គិតជាលានដុល្លារអាមេរិក) | | | | | |
|---|---|---|---|---|---|
| | **2012** | **2016** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | 2 | 52 | 792 | 740 | 1,192 |
| ទៅសហភាពអឺរ៉ុប | 1 | 33 | 130 | 91 | 93 |
| ទៅប្រទេសផ្សេងៗ | 7 | 56 | 157 | 134 | 210 |
| ow ជប៉ុន | - | - | *59* | *48* | *54* |
| ow ចិន | - | - | *28* | *24* | *41* |
| ow ចក្រភពអង់គ្លេស | - | - | - | - | *9* |
| សរុប | **10.5** | **140** | **1,079** | **965** | **1,495** |
| អត្រាកំណើននៃការនាំចេញផលិតផលធ្វើដំណើរ (ពីមួយឆ្នាំទៅមួយឆ្នាំ % r) | | | | | |
| | **2012** | **2016** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | - | 62% | 131% | -7% | 61% |
| ទៅសហភាពអឺរ៉ុប | - | 83% | 20% | -30% | 2% |
| ទៅប្រទេសផ្សេងៗ | - | 13% | 49% | -14% | 56% |
| ow ជប៉ុន | - | - | *19%* | *-19%* | *13%* |
| ow ចិន | - | - | *83%* | *-14%* | *69%* |
| សរុប | **-** | **41%** | **94%** | **-11%** | **55%** |

| ទិសដៅទីផ្សារចម្បង (%) | | | | | |
|---|---|---|---|---|---|
| | **2012** | **2016** | **2019** | **2020** | **2021** |
| ទៅសហរដ្ឋអាមេរិក | 20% | 37% | 73% | 77% | 80% |
| ទៅសហភាពអឺរ៉ុប | 10% | 23% | 12% | 9% | 6% |
| ទៅប្រទេសផ្សេងៗ | 70% | 40% | 15% | 14% | 14% |
| ow ជប៉ុន | - | - | *5%* | *5%* | *4%* |
| ow ចិន | - | - | *3%* | *3%* | *3%* |
| ow ចក្រភពអង់គ្លេស | - | - | - | - | *1%* |
| សរុប | **100%** | **100%** | **100%** | **100%** | **100%** |

*ប្រភព៖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ/វិទ្យាស្ថានជាតិស្ថិតិ។*

សម្គាល់៖ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) អនុលោម ធ្វើសុពលកម្ម និងដំណើរការទិន្នន័យជាច្រើនប្រភេទដែលប្រមូលបានពីប្រភពជាតិ និងអន្តរជាតិ។

សម្គាល់៖ ROW សម្តៅទៅលើបណ្តាប្រទេសផ្សេងទៀត។

សម្គាល់៖ នៅថ្ងៃទី31 ខែមករា ឆ្នាំ2020 ចក្រភពអង់គ្លេសបានដកខ្លួនចេញពីសហភាពអឺរ៉ុប និងបានចូលទៅក្នុង រយៈពេលអន្តរកាល។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 រយៈពេលអន្តរកាលបានបញ្ចប់ ហើយចក្រភពអង់គ្លេសបានដកខ្លួនចេញពីទីផ្សារទោល និងសហភាពគយនៃសហភាពអឺរ៉ុបជាផ្លូវការ។ ដូច្នេះ ទីផ្សារសហភាពអឺរ៉ុបនៅរយៈពេលនៃឆ្នាំ2012-2020 សម្តៅទៅលើប្រទេសសមាជិកអឺរ៉ុបចំនួន 28 ប្រទេស ប៉ុន្តែចាប់ពីឆ្នាំ2021 តទៅ ទីផ្សារសហភាពអឺរ៉ុបសម្តៅទៅលើប្រទេសសមាជិកអឺរ៉ុបចំនួន 27 ប្រទេស (មិនមានចក្រភពអង់គ្លេស)។

ជារួម ការនាំចេញផលិតផលធ្វើដំណើររបស់កម្ពុជា បានធ្លាក់ចុះ 11% នៅឆ្នាំ2020 ដែលការធ្លាក់ចុះភាគច្រើនគឺដោយសារតែការរាតត្បាតជាសកលនៃជំងឺ។ នៅឆ្នាំដដែលនោះ៖

- នាំចេញទៅកាន់សហរដ្ឋអាមេរិកបានធ្លាក់ចុះ 7% (ធៀបទៅនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យម 129% នៅចន្លោះឆ្នាំ2016 និងឆ្នាំ2019)
- ការនាំចេញទៅកាន់ទីផ្សារផ្សេងទៀតបានធ្លាក់ចុះ 14% (ធៀបទៅនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យម 37% នៅចន្លោះឆ្នាំ2016 និងឆ្នាំ2019) និង
- ការនាំចេញទៅកាន់សហភាពអឺរ៉ុប បានធ្លាក់ចុះ 30% (ធៀបទៅនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យម 67% នៅចន្លោះឆ្នាំ2016 និងឆ្នាំ2019)

ទោះបីជាមានការថយចុះនៅឆ្នាំ2020 ក៏ដោយ ក៏វិស័យផលិតផលធ្វើដំណើរ បានងើបឡើងវិញនៅឆ្នាំ2021 ដោយមាននូវការកើនឡើងប្រចាំឆ្នាំ 55% ទៅលើការនាំចេញសរុប។ ការនាំចេញសរុបបានកើនឡើងពី 965 លានដុល្លារអាមេរិក នៅឆ្នាំ2020 ដល់ 1,495 លានដុល្លារអាមេរិក នៅឆ្នាំ2021 ដែលលើសពីតម្លៃនាំចេញមុនពេលការរាតត្បាតសកលនៃជំងឺ និងអាចរ៉ាប់រងលើការខាតទាំងអស់បានយ៉ាងងាយស្រួលនៅក្នុងការនាំចេញពីមុនដែលនាំចេញទៅកាន់សហភាពអឺរ៉ុប។ និន្នាការវិជ្ជមាននេះ ហាក់បីជាបានបន្តនៅឆ្នាំ2022 ដោយមាននូវការនាំចេញផលិតផលធ្វើដំណើរកើនឡើង 46% នៅត្រីមាសទី 1 ឆ្នាំ2022 បើធៀបទៅនឹងត្រីមាស 1 ឆ្នាំ2021។

កំណើនយ៉ាងខ្លាំងក្លានៃការនាំចេញរបស់វិស័យផលិតផលធ្វើដំណើរ ឆ្លើយតបទៅនឹងកំណើនយ៉ាងខ្លាំងក្លានៅក្នុងគម្រោងវិនិយោគផ្ទាល់ពីបរទេសផ្តោតលើផលិតផលធ្វើដំណើរ។ គម្រោងនេះ មានការកើនឡើងទាំងចំនួន និងតម្លៃវិនិយោគ បន្ទាប់ពីការពង្រីកប្រព័ន្ធអនុគ្រោះទូទៅរបស់សហរដ្ឋអាមេរិកនៅឆ្នាំ2016។ យោងតាមក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គម្រោងមួយចំនួននៃគម្រោងវិនិយោគផ្ទាល់ពីបរទេសពាក់ព័ន្ធនឹងផលិតផលធ្វើដំណើរចំនួន 131 គម្រោង ត្រូវបានអនុម័តនៅក្នុងរយៈពេល 10 ឆ្នាំកន្លងមក (ឆ្នាំ2012–2021) ដែលស្មើនឹងចំនួនទឹកប្រាក់ 650 លានដុល្លារអាមេរិកនៃទ្រព្យសកម្មរយៈពេលវែង។ ក្នុងចំនោមគម្រោងទាំង 131 ទាំងនោះ គម្រោងចំនួន 109 គឺត្រូវបានអនុម័តនៅក្នុងរយៈពេលពាក់កណ្តាល (ឆ្នាំ2017-2021) នៃរយៈពេល 10 ឆ្នាំ បន្ទាប់ពីការពង្រីកប្រព័ន្ធអនុគ្រោះទូទៅរបស់សហរដ្ឋអាមេរិក។

គម្រោងភាគច្រើន នៃគម្រោងទាំងនេះ គឺសម្រាប់ផលិតកម្មកែច្នៃកាបូប គ្រឿងបន្ទាប់បន្សំកាបូន និងស្បែក។ គម្រោងផលិតកម្មកាបូបធ្វើដំណើរដែលបានអនុម័ត គឺមានតិចតួចនៅក្នុងរយៈពេលដែលបង្ហាញ។ យកឆ្នាំ2021 ជាឧទាហរណ៍ គម្រោងវិនិយោគផ្ទាល់ពីបរទេសពាក់ព័ន្ធនឹងផលិតផលធ្វើដំណើរចំនួន 16 គម្រោង ត្រូវបានអនុម័ត ដែលក្នុងចំណោមនោះ មានតែគម្រោងផលិតកម្មកាបូបធ្វើដំណើរតែមួយប៉ុណ្ណោះ។ តួលេខនេះបង្ហាញឱ្យឃើញថាកម្រិតទំនើបកម្មនៅក្នុងវិស័យផលិតផលធ្វើដំណើរកម្ពុជា នៅមានកម្រិតទាប ដោយសារតែផលិតកម្មកាបូបធ្វើដំណើរ គឺត្រូវបានចាត់ទុកជាពិសេសថាជាសកម្មភាពតម្លៃបន្ថែមខ្ពស់ជាងគេ។ ដូចគ្នាទៅនឹងវិស័យទាំងអស់ដែរ បច្ចុប្បន្ននេះ កម្ពុជាព្យាយាមផ្លាស់ទីបន្ថែមទៀតទៅលើខ្សែច្រវ៉ាក់តម្លៃសកល ហើយនឹងទំនងព្យាយាមបង្កើនចំនួនគម្រោងផលិតកម្មកាបូបធ្វើដំណើរនៅពេលអនាគត។

កំណើននៃវិស័យផលិតផលធ្វើដំណើរ ពិតណាស់គឺត្រូវបានអមជាមួយនឹងការបង្កើនចំនួនរោងចក្រផលិតផលធ្វើដំណើរដែលបានចុះបញ្ជីផ្លូវការ ក៏ដូចជាការបង្កើនចំនួនកម្មករនិយោជិតដែលជ្រើសរើសមកបម្រើការងារ។ នៅឆ្នាំ2019 កម្មករនិយោជិតវិស័យផលិតផលធ្វើដំណើរចំនួន 46,207 នាក់ បានធ្វើការនៅក្នុងរោងចក្រចំនួន 91 រោងចក្រ។ នៅឆ្នាំ2021 ចំនួនកម្មករនិយោជិតនោះបានមានការកើនឡើងដល់ 84,686 នាក់នៅទូទាំងរោងចក្រដែលបានចុះបញ្ជីចំនួន 121 រោងចក្រ។

ឆ្នាំ2022 គឺជាឆ្នាំមួយដែលជារយៈពេលបូកសរុប។ ទោះបីជាមានការធ្លាក់ចុះបន្តិចទៅលើចំនួនរោងចក្រផលិតផលធ្វើដំណើរដែលបានចុះបញ្ជីមកត្រឹម 114 រោងចក្រ (ធៀបនឹង 121 រោងចក្រ) ក៏ដោយ ក៏ចំនួនកម្មករនិយោជិត បានកើនឡើងដល់ 98,282 នាក់ (ធៀបនឹង 84,686 នាក់)។

ប្រាក់បៀវត្សរោងចក្រផលិតផលធ្វើដំណើរ ក៏បានកើនឡើងផងដែរ ស្របគ្នាជាមួយនឹងតម្លៃនាំចេញ និងចំនួនកម្មករនិយោជិត។ ប្រាក់បៀវត្សប្រចាំឆ្នាំនៃវិស័យផលិតផលធ្វើដំណើរ បានកើនឡើងពី 130 លានដុល្លារអាមេរិក នៅឆ្នាំ2019 ដល់ 285 លានដុល្លារអាមេរិកនៅឆ្នាំ2021។

ទាំងប្រាក់ចំណូលប្រចាំខែជាមធ្យមពិត និងណូមីណាល់ (រួមទាំងប្រាក់ការងារបន្ថែមម៉ោង និងប្រាក់ឧបត្ថម្ភ) របស់កម្មករនិយោជិតនៅក្នុងវិស័យផលិតផលធ្វើដំណើរ បានកើនឡើងជាលំដាប់នៅក្នុងរយៈពេលនេះ។ ប្រាក់ចំណូលប្រចាំខែណូមីណាល់របស់កម្មករនិយោជិតនៃវិស័យផលិតផលធ្វើដំណើររបស់កម្ពុជា បានកើនឡើងពី US$ 235 (ឆ្នាំ2019) ដល់ US$ 238 (ឆ្នាំ2020) និងបន្តកើនឡើងដល់ US$ 278 (ឆ្នាំ2021)។ ប្រាក់ចំណូលនេះបានធ្លាក់ចុះបន្តិចទៅដល់ US$ 276 នៅក្នុងត្រីមាសទី 1 នៃឆ្នាំ2022។ ស្របពេលជាមួយគ្នានេះ ចំណូលប្រចាំខែពិតដែលបានធ្វើនិយតកម្មអតិផរណារបស់កម្មករនិយោជិតនៃវិស័យផលិតផលធ្វើដំណើរ គឺមានកម្រិតទាប ដែលដំបូងធ្លាកចុះពី US$ 225 (ឆ្នាំ2019) ដល់ US$ 222 (ឆ្នាំ2020) និងកើនឡើងដល់ US$ 251 (ឆ្នាំ2021) មុនពេលធ្លាក់ចុះដល់ US$ 240 នៅក្នុងត្រីមាសទី 1 ឆ្នាំ2022។

## ៨. សេចក្តីសន្និដ្ឋាន

ការរាតត្បាតជាសកលនៃជំងឺកូវីដ-19 បាននាំឱ្យមានការថយចុះដំបូងនៅក្នុងការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ពីប្រទេសកម្ពុជា ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុ ឆ្នាំ2009 មក។ ផលិតផលក្នុងស្រុកសរុបពិត បានធ្លាក់ចុះយ៉ាងគំហុក 3.1% នៅឆ្នាំ2020 ហើយកម្មករនិយោជិតនៃវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរស្ទើរតែជិត 45,000 នាក់ បានបាត់បង់ការងារ និងប្រភពចំណូលចម្បងនៅចន្លោះឆ្នាំ2020 និងឆ្នាំ2021។ ការពឹងផ្អែករបស់កម្ពុជាទៅលើវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរជាវិស័យរួមចំណែកចម្បងដល់កំណើនសេដ្ឋកិច្ច ក៏ដូចជាចំណូលគ្រួសារឯកជន មានន័យថាការថយចុះណាមួយទៅលើការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ គឺទំនងជាមានឥទ្ធិពលខ្លាំង។ ការដកចេញដោយផ្នែកនៃគំនិតផ្តួចផ្តើមប្រព័ន្ធអនុគ្រោះអ្វីគ្រប់យ៉ាងលើកលែងតែអាវុធរបស់សហភាពអឺរ៉ុប មិនបានជួយសម្រួលដល់ស្ថានភាពនោះទេ ទោះបីជាផលប៉ះពាល់អវិជ្ជមាននៃការដកចេញដោយផ្នែកនេះ មិនមានភាពធ្ងន់ធ្ងរដូចដែលប្រជាជនជាច្រើនមានការភ័យខ្លាចក៏ដោយ ដោយការនាំចេញជាចម្បងទៅកាន់សហភាពអឺរ៉ុបមានការថយចុះនៅក្នុងវិស័យផលិតផលធ្វើដំណើរ (ហើយភាគច្រើនទៅលើចំណែកនៃការនាំចេញ មិនមែនបរិមាណនាំចូលសរុបនោះទេ)។

បើសម្លឹងឱ្យវែងឆ្ងាយ ការគ្រប់គ្រងប្រកបដោយភាពរហ័ស និងសមត្ថភាពរបស់រដ្ឋាភិបាលទៅលើការរាតត្បាតនៃជំងឺ ពិតជាបានគាំទ្រដល់ការស្តារឡើងវិញយ៉ាងរហ័សជាងអ្វីដែលបានរំពឹងទុកទៅទៀត។ ឆ្នាំ2021 បានបង្ហាញអំពីសញ្ញាសង្ឃឹមនៃការស្តារប្រទេសឡើងវិញបានយ៉ាងល្អរួចទៅហើយ។ នៅឆ្នាំ2021 ធៀបនឹងឆ្នាំ2020 ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរទាំងមូល បានកើនឡើង 15% និងការនាំចេញផលិតផលធ្វើដំណើរ បានកើនឡើង 55%។ ក្នុងចំណោមអនុវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ (សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ) ការនាំចេញនៅឆ្នាំ2021 មានកម្រិតលើសពីការនាំចេញផលិតផលស្បែកជើង

និងផលិតផលធ្វើដំណើរនៅមុនពេលការរាតត្បាតនៃជំងឺទៅទៀត (ឆ្នាំ2019)។ កន្លងមកនេះ និន្នាការទាំងនេះទំនងជាបន្តនៅឆ្នាំ2022 (ផ្អែកលើទិន្នន័យនៅត្រីមាសទី 1 ឆ្នាំ2022) ហើយអនុវិស័យកាត់ដេរ (រួមទាំងវាយនភណ្ឌ) ព្យាយាមកំណត់សម្រេចឱ្យបានតម្លៃនាំចេញលើសពីតម្លៃនាំចេញមុនពេលការរាតត្បាតនៃជំងឺ (ឆ្នាំ2019) នៅត្រឹមចុងឆ្នាំ2022។

ទោះជាយ៉ាងនេះក្ដី វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ (និងសូម្បីតែវិស័យផលិតផលធ្វើដំណើរ) នៅតែពឹងផ្អែកយ៉ាងខ្លាំងនៅឡើយទៅលើទិសដៅនាំចេញតិចពោលគឺ សហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប ហើយការអនុគ្រោះពាណិជ្ជកម្មពាក់ព័ន្ធដែលទីផ្សារទាំងនេះបានផ្ដល់ជូននាពេលបច្ចុប្បន្ន។ ឧទាហរណ៍ ការពង្រីកប្រព័ន្ធអនុគ្រោះទូទៅរបស់សហរដ្ឋអាមេរិក បាន និងកំពុងជាវិស័យរួមចំណែកចម្បងមួយចំពោះកំណើនយ៉ាងរហ័សនៃវិស័យផលិតផលធ្វើដំណើររបស់កម្ពុជា ដោយសារតែវិស័យនេះបានកើនឡើតពី 0.02% នៃចំណែកទីផ្សារសកល នៅឆ្នាំ2012 ទៅចំណែក 1.6% នៅឆ្នាំ2021។

ទោះបីជាការអនុគ្រោះទាំងនេះអាចនឹងនាំឱ្យមានកំណើនសេដ្ឋកិច្ចរយៈពេលខ្លី និងរយៈពេលវែងក៏ដោយ (និងពិតជាបាននាំឱ្យមានកំណើនសេដ្ឋកិច្ចរយៈពេលវែងកាលពីអតីតកាលប្រាកដមែន) ប្រព័ន្ធអនុគ្រោះទាំងនេះក៏ធ្វើឱ្យវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជាងាយរងគ្រោះទៅនឹងឥទ្ធិពលខាងក្រៅផងដែរ។ ឧទាហរណ៍ ដោយផលិតផលធ្វើដំណើរកម្ពុជាចំនួន 80% បាននាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ការប្រែប្រួលបន្តិចទៅលើប្រព័ន្ធអនុគ្រោះទូទៅរបស់សហរដ្ឋអាមេរិក អាចនឹងនាំឱ្យផលប៉ះពាល់ជាពិសេសដល់វិស័យផលិតផលធ្វើដំណើរដែលកំពុងតែដុះពន្លកមកនេះ។

យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ ឆ្នាំ2022–2027 ថ្មីរបស់រដ្ឋាភិបាល បង្កើតបានជាជំហានដ៏សំខាន់មួយក្នុងការឆ្ពោះទៅមុខក្នុងការដោះស្រាយបញ្ហាប្រឈមដែលវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរកម្ពុជាជួបប្រទះ។ ដូចគ្នានេះដែរ ច្បាប់ស្ដីពីការវិនិយោគថ្មី ក៏ត្រូវបានសង្ឃឹមថានឹងជំរុញដល់ការវិនិយោគបន្ថែមទៅលើវិស័យផលិតផលធ្វើដំណើររបស់កម្ពុជា និងទៅលើការបង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពផលិតបច្ចុប្បន្ន។

ដោយយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរបានកំណត់អត្តសញ្ញាណហានិភ័យ និងឱកាសចម្បងៗ ចីរភាព និងលទ្ធភាពប្រកួតប្រជែងរយៈពេលវែងរបស់វិស័យនេះ បច្ចុប្បន្នគឺពឹងផ្អែកលើការអនុវត្តយុទ្ធសាស្រ្ត និងវិធានការដ៏រឹងមាំ។ អ្នកបង្កើតគោលនយោបាយ ម៉ាក និងម្ចាស់រោងចក្រ ចាំបាច់ត្រូវតែដឹងអំពីទិន្នាការខាងមុខ (ដូចជា ការពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស បរិស្ថាន ច្បាប់ និងការធ្វើឌីជីថលនីយកម្មការផលិត) និងហានិភ័យនៃការពឹងផ្អែកហួសហេតុទៅលើប្រព័ន្ធអនុគ្រោះជាមួយដៃគូពាណិជ្ជកម្មធំៗ។

តួលេខពីឆ្នាំ2021 និងឆ្នាំ2022 សបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថាវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ គឺកំពុងតែងើបឡើងវិញបានយ៉ាងល្អប្រសើរ ហើយនឹងនៅតែជាវិស័យសំខាន់សម្រាប់កម្ពុជា នៅក្នុងរយៈពេលមធ្យម។ ការរៀបចំផែនការ ការធ្វើពិពិធកម្ម និងការបំប៉នជំនាញសមស្រប បច្ចុប្បន្ននេះអាចធានាបានថា វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរកម្ពុជា គឺស្ថិតនៅលើជំហរល្អប្រសើរ និងមានលទ្ធភាពក្នុងការធានានូវភាពជាប់ពាក់ព័ន្ធជាមជ្ឈមណ្ឌលផលិតគិតទៅលើអនាគតសម្រាប់ឆ្នាំបន្តបន្ទាប់។

**ឧបសម្ព័ន្ធ 1. វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា – សូចនាករដែលបានជ្រើសរើស**

| | 2019 | | | | 2020 | | | | | 2021 | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | **2019** | Q1 | Q2 | Q3 | Q4 | **2020** | Q1 | Q2 | Q3 | Q4 | **2021** | Q1 |
| **1. ធាតុចេញសេដ្ឋកិច្ច** | | | | | | | | | | | | | | | |
| **ផសសស (% កំណើនពិត)** | - | - | - | **7.1** | - | - | - | - | **-3.1** | - | - | - | - | **3.0** | - |
| **ផសសស(% កំណើនណូមីណាល់)** | - | - | - | **15.5** | - | - | - | - | **-3.7** | - | - | - | - | **4.4** | - |
| **ផសសស (តម្លៃបច្ចុប្បន្ន លានដុល្លារអាមេរិក)** | - | - | - | **27 030** | - | - | - | - | **25 967** | - | - | - | - | **27 167** | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និង ស្បែកជើង តម្លៃបច្ចុប្បន្ន លានដុល្លារអាមេរិក) | - | - | - | **2 899** | - | - | - | - | **2 542** | - | - | - | - | **2 924** | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និង ស្បែកជើង % នៃផសសស) | - | - | - | **10.7** | - | - | - | - | **9.8** | - | - | - | - | **10.8** | - |
| **ការនាំចេញទំនិញសរុបរបស់ប្រទេស (លានដុល្លារអាមេរិក)** | - | - | - | **14,986** | - | - | - | - | **18,522** | - | - | - | - | **19,703** | |
| **2. ការនាំចេញសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ** | | | | | | | | | | | | | | | |
| ***2a. ការនាំចេញ និងកំណើនសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ*** | | | | | | | | | | | | | | | |
| **ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង(លានដុល្លារអាមេរិក)** [1/] | **2,556** | **3,143** | **2,651** | **10,840** | **2,645** | **1,934** | **2,640** | **2,549** | **9,768** | **2,480** | **2,147** | **3,461** | **3,104** | **11,191** | **3,104** |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | | | | | | -24.3 | -16.0 | -3.8 | **-9.9** | -6.2 | 11.0 | 31.1 | 21.8 | **14.6** | 25.2 |
| ការនាំចេញសម្លៀកបំពាក់ (លានដុល្លារអាមេរិក) | 1,975 | 2,529 | 2,025 | **8,497** | 1,964 | 1,536 | 2,164 | 2,023 | **7,687** | 1,843 | 1,521 | 2,682 | 2,259 | **8,304** | 2,214 |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | | | | | | -22.2 | -14.4 | -0.1 | **-9.5** | -6.1 | -1.0 | 24.0 | 11.6 | **8.0** | 20.1 |
| ការនាំចេញស្បែកជើង (លានដុល្លារអាមេរិក) | 319 | 316 | 353 | **1,265** | 341 | 263 | 243 | 270 | **1,117** | 317 | 322 | 360 | 394 | **1,392** | 421 |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | | | | | | -17.5 | -23.1 | -23.6 | **-11.7** | -7.3 | 22.4 | 48.2 | 46.1 | **24.7** | 33.2 |
| ការនាំចេញផលិតផលធ្វើដំណើរ (លានដុល្លារអាមេរិក) | 263 | 299 | 273 | **1,079** | 340 | 135 | 233 | 256 | **965** | 320 | 305 | 419 | 451 | **1,495** | 468 |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | | | | | | -48.6 | -21.9 | -6.1 | **-10.6** | -5.9 | 125.7 | 79.4 | 76.0 | **54.9** | 46.5 |
| **ការនាំចូលវត្ថុធាតុកាត់ដេររក្សាទុក (លានដុល្លារអាមេរិក)** | **1,162** | **985** | **1,190** | **4,289** | **881** | **861** | **1,094** | **1,199** | **4,035** | **1,039** | **1,211** | **1,312** | **1,525** | **5,086** | **n/a** |

## 2b. ការនាំចេញ និងកំណើនសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរតាមទិសដៅចម្បងៗ

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការនាំចេញសរុប (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ) (លានដុល្លារអាមេរិក)** | **2,556** | **3,143** | **2,651** | **10,840** | **2,645** | **1,934** | **2,640** | **2,549** | **9,768** | **2,480** | **2,147** | **3,461** | **3,104** | **11,191** | **3,104** |
| ទៅសហរដ្ឋអាមេរិក (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ)[1/] | 820 | 1,017 | 875 | **3,462** | 956 | 674 | 999 | 957 | **3,585** | 1,008 | 949 | 1,510 | 1,360 | **4,827** | 1,346 |
| ទៅសហភាពអឺរ៉ុប (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ)[1/] | 1,022 | 1,259 | 1,008 | **4,257** | 914 | 708 | 891 | 897 | **3,410** | 583 | 529 | 827 | 787 | **2,726** | 763 |
| ទៅប្រទេសផ្សេងទៀត (សម្លៀកបំពាក់ និង ស្បែកជើង)[1/] | 715 | 868 | 768 | **3,121** | 775 | 553 | 750 | 696 | **2,773** | 889 | 670 | 1,123 | 956 | **3,638** | 995 |
| o/w ជប៉ុន | 180 | 293 | 247 | **988** | 265 | 154 | 230 | 220 | **869** | 240 | 144 | 297 | 217 | **898** | 247 |
| o/w ចិន | 85 | 93 | 85 | **348** | 99 | 58 | 90 | 63 | **310** | 96 | 50 | 84 | 74 | **303** | 84 |
| o/w ចក្រភពអង់គ្លេស | - | - | - | **-** | - | - | - | - | **-** | 144 | 107 | 211 | 179 | **641** | 172 |
| **ការនាំចេញសរុប (សម្លៀកបំពាក់ប៉ុណ្ណោះ លានដុល្លារអាមេរិក)[1/]** | **1,975** | **2,529** | **2,025** | **8,497** | **1,964** | **1,536** | **2,164** | **2,023** | **7,687** | **1,843** | **1,521** | **2,682** | **2,259** | **8,304** | **2,214** |
| ទៅសហរដ្ឋអាមេរិក (សម្លៀកបំពាក់)[1/] | 558 | 717 | 581 | **2,369** | 600 | 513 | 753 | 681 | **2,546** | 653 | 594 | 1,038 | 851 | **3,136** | 819 |
| ទៅសហភាពអឺរ៉ុប (សម្លៀកបំពាក់)[1/] | 831 | 1,078 | 826 | **3,541** | 739 | 570 | 779 | 777 | **2,865** | 477 | 419 | 709 | 646 | **2,250** | 613 |
| ទៅកាន់ប្រទេសផ្សេងទៀត (សម្លៀកបំពាក់)[1/] | 586 | 734 | 618 | **2,586** | 625 | 454 | 632 | 565 | **2,275** | 714 | 507 | 934 | 762 | **2,917** | 782 |
| o/w ជប៉ុន | 146 | 259 | 210 | **847** | 223 | 130 | 202 | 184 | **738** | 200 | 111 | 261 | 182 | **753** | 206 |
| o/w ចិន | 65 | 74 | 62 | **268** | 71 | 40 | 65 | 44 | **220** | 68 | 30 | 51 | 50 | **199** | 53 |
| o/w ចក្រភពអង់គ្លេស | - | - | - | **-** | - | - | - | - | **-** | 127 | 90 | 192 | 157 | **566** | 147 |
| **ការនាំចេញសរុប (ស្បែកជើងប៉ុណ្ណោះ លានដុល្លារអាមេរិក)** | **319** | **316** | **353** | **1,265** | **341** | **263** | **243** | **270** | **1,117** | **317** | **322** | **360** | **394** | **1,392** | **421** |
| ទៅសហរដ្ឋអាមេរិក (ស្បែកជើង) | 71 | 75 | 95 | **301** | 95 | 57 | 68 | 79 | **299** | 105 | 115 | 130 | 149 | **499** | 152 |
| ទៅសហភាពអឺរ៉ុប (ស្បែកជើង) | 156 | 147 | 151 | **586** | 141 | 124 | 91 | 98 | **454** | 88 | 90 | 94 | 111 | **383** | 117 |
| ទៅប្រទេសផ្សេងទៀត (ស្បែកជើង) | 92 | 94 | 107 | **378** | 105 | 82 | 83 | 93 | **363** | 124 | 116 | 137 | 133 | **510** | 152 |
| o/w ជប៉ុន | 20 | 19 | 21 | **82** | 25 | 18 | 17 | 22 | **83** | 26 | 19 | 24 | 22 | **90** | 29 |
| o/w ចិន | 13 | 12 | 15 | **51** | 19 | 16 | 18 | 12 | **66** | 17 | 13 | 23 | 11 | **63** | 16 |
| o/w ចក្រភពអង់គ្លេស | - | - | - | **-** | - | - | - | - | **-** | 16 | 15 | 17 | 20 | **67** | 23 |



| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការនាំចេញសរុប (ផលិតផលធ្វើដំណើរប៉ុណ្ណោះ លានដុល្លារអាមេរិក)** | **263** | **299** | **273** | **1,079** | **340** | **135** | **233** | **256** | **965** | **320** | **305** | **419** | **451** | **1,495** | **468** |
| ទៅសហរដ្ឋអាមេរិក (ស្បែកជើង) | 191 | 225 | 200 | **792** | 261 | 104 | 178 | 197 | **740** | 250 | 240 | 342 | 360 | **1,192** | 374 |
| ទៅសហភាពអឺរ៉ុប (ស្បែកជើង) | 34 | 33 | 31 | **130** | 34 | 14 | 21 | 22 | **91** | 19 | 19 | 25 | 30 | **93** | 33 |
| ទៅប្រទេសផ្សេងទៀត (ស្បែកជើង) | 37 | 40 | 42 | **157** | 45 | 17 | 35 | 37 | **134** | 51 | 46 | 52 | 61 | **210** | 61 |
| o/w ជប៉ុន | 14 | 15 | 16 | **59** | 17 | 6 | 11 | 14 | **48** | 14 | 15 | 12 | 13 | **54** | 12 |
| o/w ចិន | 7 | 7 | 8 | **28** | 9 | 2 | 7 | 7 | **24** | 11 | 7 | 10 | 13 | **41** | 14 |
| o/w ចក្រភពអង់គ្លេស | - | - | - | **-** | - | - | - | - | **-** | 2 | 2 | 2 | 3 | **9** | 3 |

# 3. ការវិនិយោគថ្មី ការបើក និងការបិទរោងចក្រ

## 3a. គម្រោងវិនិយោគថ្មី *

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **គម្រោងវិនិយោគសរុបអនុម័តដោយក្រុមប្រឹក្សាវិនិយោគកម្ពុជា** | **37** | **49** | **48** | **197** | **45** | **55** | **21** | **33** | **154** | **28** | **25** | **30** | **25** | **108** | **40** |
| **មាន៖ គម្រោងសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ [1/]** | **15** | **24** | **27** | **112** | **31** | **22** | **12** | **15** | **80** | **14** | **15** | **19** | **15** | **63** | **24** |
| គម្រោងសម្លៀកបំពាក់ | 9 | 11 | 15 | **52** | 22 | 12 | 9 | 12 | **55** | 10 | 7 | 10 | 12 | **39** | 19 |
| គម្រោងស្បែកជើង | 2 | 2 | 2 | **9** | 3 | 5 | 1 | 2 | **11** | 2 | 2 | 3 | 1 | **8** | 1 |
| គម្រោងផលិតផលធ្វើដំណើរ | 4 | 11 | 10 | **51** | 6 | 5 | 2 | 1 | **14** | 2 | 6 | 6 | 2 | **16** | 4 |
| **គម្រោងសរុបអនុម័តដោយក្រុមប្រឹក្សាវិនិយោគកម្ពុជា (លានដុល្លារអាមេរិក)** | **2,687** | **1,153** | **2,385** | **8,160** | **916** | **1,254** | **3,696** | **1,663** | **7,529** | **680** | **262** | **194** | **583** | **1,719** | **2,107** |
| **មាន៖ គម្រោងសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ (លានដុល្លារអាមេរិក) [1/]** | **84** | **105** | **134** | **562** | **142** | **104** | **51** | **74** | **371** | **55** | **61** | **112** | **63** | **291** | **114** |
| គម្រោងសម្លៀកបំពាក់ (លានដុល្លារអាមេរិក) | 33 | 46 | 72 | **226** | 106 | 57 | 35 | 44 | **241** | 37 | 27 | 82 | 52 | **198** | 92 |
| គម្រោងស្បែកជើង (លានដុល្លារអាមេរិក) | 27 | 10 | 12 | **62** | 14 | 20 | 10 | 24 | **69** | 11 | 12 | 11 | 3 | **37** | 2 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គម្រោងផលិតផលធ្វើដំណើរ (លានដុល្លារអាមេរិក) | 24 | 49 | 50 | **274** | 22 | 27 | 6 | 6 | **61** | 6 | 22 | 20 | 8 | **56** | 20 |

### *3b. ការបើក និងបិទរោងចក្រ (រោងចក្របានចុះបញ្ជី)1/*

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំនួនសរុបនៃរោងចក្រកាត់ដេរ ស្បែកជើង ផលិតផលធ្វើដំណើរ (ចុងគ្រា)** | **807** | **828** | **852** | **852** | **878** | **711** | **722** | **739** | **739** | **716** | **724** | **749** | **718** | **718** | **689** |
| រោងចក្រកាត់ដេរ (e.o.p) | 648 | 661 | 675 | **675** | 688 | 535 | 543 | 556 | **556** | 536 | 542 | 550 | 530 | **530** | 507 |
| រោងចក្រស្បែកជើង (e.o.p) | 83 | 84 | 86 | **86** | 88 | 75 | 77 | 79 | **79** | 71 | 73 | 77 | 67 | **67** | 68 |
| រោងចក្រផលិតផលធ្វើដំណើរ (e.o.p) | 76 | 83 | 91 | **91** | 102 | 101 | 102 | 104 | **104** | 109 | 109 | 122 | 121 | **121** | 114 |
| **ការបើកសុទ្ធសរុប (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ)1/** | **20** | **21** | **24** | **144** | **26** | **-167** | **11** | **17** | **-113** | **-23** | **8** | **25** | **-31** | **-21** | **-29** |
| រោងចក្រកាត់ដេរ | 15 | 13 | 14 | **50** | 13 | -153 | 8 | 13 | **-119** | -20 | 6 | 8 | -20 | **-26** | -23 |
| រោងចក្រស្បែកជើង | 0 | 1 | 2 | **3** | 2 | -13 | 2 | 2 | **-7** | -8 | 2 | 4 | -10 | **-12** | 1 |
| រោងចក្រផលិតផលធ្វើដំណើរ | 5 | 7 | 8 | **91** | 11 | -1 | 1 | 2 | **13** | 5 | 0 | 13 | -1 | **17** | -7 |
| **ការបើក (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ)1/** | **20** | **25** | **24** | **154** | **26** | **23** | **11** | **18** | **78** | **22** | **8** | **25** | **15** | **70** | **10** |
| រោងចក្រកាត់ដេរ | 15 | 13 | 14 | **50** | 13 | 18 | 8 | 14 | **53** | 11 | 6 | 8 | 12 | **37** | 11 |
| រោងចក្រស្បែកជើង | 0 | 2 | 2 | **4** | 2 | 2 | 2 | 2 | **8** | 4 | 2 | 4 | 1 | **11** | 1 |
| រោងចក្រផលិតផលធ្វើដំណើរ | 5 | 10 | 8 | **100** | 11 | 3 | 1 | 2 | **17** | 7 | 0 | 13 | 2 | **22** | -2 |
| **ការបិទ (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ)1/** | **0** | **4** | **0** | **10** | **0** | **190** | **0** | **1** | **191** | **45** | **0** | **0** | **46** | **91** | **39** |
| រោងចក្រកាត់ដេរ | 0 | 0 | 0 | **0** | 0 | 171 | 0 | 1 | **172** | 31 | 0 | 0 | 32 | **63** | 34 |
| រោងចក្រស្បែកជើង | 0 | 1 | 0 | **1** | 0 | 15 | 0 | 0 | **15** | 12 | 0 | 0 | 11 | **23** | 0 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រោងចក្រផលិតផលធ្វើដំណើរ | 0 | 3 | 0 | **9** | 0 | 4 | 0 | 0 | **4** | 2 | 0 | 0 | 3 | **5** | 5 |

## 4. ការងារនៅក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **សរុបកម្មករនិយោជិតវិស័យកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ (រយៈពេលមធ្យម '000) 2/** | **708** | **721** | **732** | **715** | **769** | **708** | **670** | **673** | **705** | **679** | **661** | **667** | **680** | **672** | **663** |
| % ប្រែប្រួល (ពីមួយឆ្នាំទៅមួយឆ្នាំ) | | | | | | 0.0 | -7.1 | -8.1 | **-1.4** | -11.8 | -6.7 | -0.4 | 1.0 | **-4.7** | -2.3 |
| កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរ (រយៈពេលមធ្យម '000) | 551 | 557 | 560 | **553** | 571 | 504 | 470 | 469 | **504** | 475 | 459 | 458 | 459 | **463** | 447 |
| កម្មករនិយោជិតនៅក្នុងវិស័យស្បែកជើង (រយៈពេលមធ្យម '000) | 113 | 117 | 123 | **116** | 136 | 133 | 126 | 128 | **131** | 124 | 121 | 126 | 126 | **124** | 117 |
| កម្មករនិយោជិតនៅក្នុងវិស័យផលិតផលធ្វើដំណើរ (រយៈពេលមធ្យម '000) | 45 | 47 | 49 | **46** | 62 | 71 | 75 | 75 | **71** | 79 | 81 | 84 | 95 | **85** | 98 |

## 5. ប្រាក់ឈ្នួល និងតម្លៃ

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ឈ្នួលអប្បបរមា (វិស័យកាត់ដេរ និងស្បែកជើង ដុល្លារអាមេរិក)** | **182** | **182** | **182** | **182** | **190** | **190** | **190** | **190** | **190** | **192** | **192** | **192** | **192** | **192** | **194** |
| **ប្រាក់ឈ្នួលប្រចាំខែមធ្យម (សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ ដុល្លារអាមេរិក)2/ 3/** | **232** | **232** | **236** | **232** | **231** | **238** | **231** | **234** | **234** | **245** | **242** | **261** | **277** | **256** | **263** |
| ប្រាក់ឈ្នួលប្រចាំខែមធ្យម (កម្មករនិយោជិតកាត់ដេរ ដុល្លារអាមេរិក)2/ | 230 | 234 | 238 | **232** | 237 | 241 | 247 | 246 | **243** | 247 | 243 | 252 | 287 | **257** | 278 |
| ប្រាក់ឈ្នួលប្រចាំខែមធ្យម (កម្មករនិយោជិតស្បែកជើង ដុល្លារអាមេរិក)2/ | 226 | 227 | 234 | **228** | 216 | 227 | 214 | 221 | **219** | 235 | 234 | 234 | 233 | **234** | 234 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់ឈ្នួលប្រចាំខែមធ្យម (កម្មករនិយោជិត ផលិតផលធ្វើដំណើរ ដុល្លារអាមេរិក)[2] | 239 | 236 | 234 | **235** | 240 | 246 | 232 | 236 | **238** | 254 | 247 | 298 | 311 | **278** | 276 |
| **ប្រាក់ឈ្នួលប្រចាំខែមធ្យមពិត (តម្លៃសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ ឆ្នាំ2017 ដុល្លារអាមេរិក)[4]** | **222** | **221** | **224** | **222** | **217** | **223** | **214** | **215** | **217** | **225** | **220** | **235** | **246** | **232** | **228** |
| ប្រាក់ឈ្នួលប្រចាំខែពិត (សម្លៀកបំពាក់ ឆ្នាំ2017 ដុល្លារអាមេរិក)[4] | 221 | 223 | 226 | **222** | 223 | 226 | 230 | 226 | **226** | 227 | 221 | 226 | 254 | **232** | 241 |
| ប្រាក់ឈ្នួលប្រចាំខែពិត (ស្បែកជើង ឆ្នាំ2017 ដុល្លារអាមេរិក)[4] | 217 | 217 | 222 | **219** | 203 | 213 | 199 | 202 | **204** | 216 | 213 | 210 | 207 | **212** | 203 |
| ប្រាក់ឈ្នួលប្រចាំខែមធ្យមពិត (ផលិតផលធ្វើដំណើរ ឆ្នាំ2017 ដុល្លារអាមេរិក)[4] | 229 | 225 | 222 | **225** | 225 | 230 | 215 | 217 | **222** | 233 | 225 | 267 | 276 | **251** | 240 |
| **សន្ទស្សន៍តម្លៃទំនិញអ្នកប្រើប្រាស់ (រយៈពេលមធ្យម) មូលដ្ឋានថ្មី ឆ្នាំ2017=100** | **104.2** | **104.9** | **105.3** | **104.4** | **106.5** | **106.8** | **107.8** | **108.9** | **107.5** | **108.8** | **109.8** | **111.3** | **112.7** | **110.7** | **115.2** |
| **អត្រាអតិផរណា (រយៈពេលមធ្យម កំណើនប្រចាំឆ្នាំ)** | 1.8% | 2.0% | 2.0% | **1.9%** | 3.0% | 2.5% | 2.8% | 3.4% | **2.9%** | 2.1% | 2.8% | 3.2% | 3.5% | **2.9%** | 5.9% |

សម្គាល់៖ អត្រាកំណើន ផសស គឺបានមកពី វិទ្យាស្ថានជាតិស្ថិតិ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

1. រួមបញ្ចូលវាយនភណ្ឌ
2. អត្រានេះត្រូវបានគណនា ដោយផ្អែកលើស្ថិតិដែលបានកត់ត្រាជាផ្លូវការរបស់ក្រសួងពាណិជ្ជកម្មអំពីរោងចក្រប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ ទិន្នន័យនេះ មិនរួមបញ្ចូលកម្មករនិយោជិតការិយាល័យបរទេស និងអ្នកគ្រប់គ្រងបរទេស
3. យោងតាមប្រាក់ឈ្នួលប្រចាំខែមធ្យមសុទ្ធ
4. ការគណនាផ្អែកលើតម្លៃឆ្នាំ2017

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគណនារបស់អ្នកនិពន្ធ*

** គម្រោងវិនិយោគសម្តៅទៅលើគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បន្ថែម (មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកទឹកចិត្តសារពើពន្ធ) និងគម្រោងវិនិយោគមានការធានា (មិនមានការលើកទឹកចិត្តសារពើពន្ធ)។*



# កំណត់ចំណាំសំខាន់ៗ

1. *សូមមើលឧបសម្ព័ន្ធ 1៖ ការវិភាគ និងការបង្ហាញនៅក្នុងឯកសារសង្ខេបអំពីវិស័យ គឺផ្អែកលើស្ថិតិផ្លូវការពីប្រភពផ្លូវការជាច្រើន រួមទាំងសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) ទីភ្នាក់ងារស្ថិតិអឺរ៉ុប (Eurostat) ក្រសួងពាណិជ្ជកម្មរបស់កម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករ វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា។ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (EUROCHAM) និង អង្គការពលកម្មអន្តរជាតិ (ILO) មានបំណងថ្លែងអំណរគុណ និងអរគុណស្ថាប័នទាំងនេះ សម្រាប់ការគាំទ្រ និងការផ្តល់ទិន្នន័យដើម្បីប្រើប្រាស់នៅក្នុងឯកសារចុះផ្សាយនេះ។*
2. *យោងតាមនិយមន័យដូចមានរៀបរាប់នៅលើការស្ទង់មតិអំពីកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ2019 (CLFS 2019) ទំព័រ 99។*
3. *ផ្អែកលើគណនីជាតិរបស់កម្ពុជា ឆ្នាំ2022 (ពី វិទ្យាស្ថានជាតិស្ថិតិ)។*
4. *សេចក្តីប្រកាសសារព័ត៌មាន (ចុះថ្ងៃទី21 ខែមីនា ឆ្នាំ2022) ស្តីពីការដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ឆ្នាំ2022–2027។*
5. *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ឆ្នាំ2022–2027 (ទំព័រ i និង ii)។*
6. *ឯកសារសង្ខេបពិសេសនៃច្បាប់ស្តីពីការវិនិយោគថ្មី (បានប្រកាសឱ្យប្រើប្រាស់កាលពីខែតុលា ឆ្នាំ2021) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសហការជាមួយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា។*
7. *ធនាគារជាតិនៃកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។*
8. *អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ខែកញ្ញា ឆ្នាំ2022។*
9. *សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី13 ខែកញ្ញា ឆ្នាំ2022 សម្រង់សម្តីរបស់អ្នកតំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (TAFTAC)។*
10. *ផ្អែកលើស្ថិតិពី ធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករ វិទ្យាស្ថានជាតិស្ថិតិកម្ពុជា។*
11. *សេចក្តីប្រកាសសារព័ត៌មានរបស់គណៈកម្មការអឺរ៉ុបស្តីពីប្រព័ន្ធអនុគ្រោះអ្វីគ្រប់យ៉ាង លើកលែងតែអាវុធរបស់កម្ពុជា នៅថ្ងៃទី12 ខែសីហា ឆ្នាំ2020 (តំណភ្ជាប់ទៅកាន់អត្ថបទ)*
12. *នៅថ្ងៃទី31 ខែមករា ឆ្នាំ2020 ចក្រភពអង់គ្លេសបានដកខ្លួនចេញពីសហភាពអឺរ៉ុប និងបានចូលទៅក្នុង រយៈពេលអន្តរកាល។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 រយៈពេលអន្តរកាលបានបញ្ចប់ ហើយចក្រភពអង់គ្លេសបានដកខ្លួនចេញពីទីផ្សារទោល និងសហភាពគយនៃសហភាពអឺរ៉ុបជាផ្លូវការ។ ដូច្នេះ "ទីផ្សារសហភាពអឺរ៉ុប" រយៈពេលពីឆ្នាំ2012-2020 សម្តៅទៅលើសមាជិកសហភាពអឺរ៉ុបចំនួន 28 ប្រទេស។ ពីឆ្នាំ2021 តទៅ "ទីផ្សារសហភាពអឺរ៉ុប" សម្តៅទៅលើសមាជិកសហភាពអឺរ៉ុបចំនួន 27 ប្រទេសប៉ុណ្ណោះ។*
13. *សេចក្តីប្រកាសសារព័ត៌មានរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិកម្ពុជា (ចុះថ្ងៃទី17 ខែធ្នូ ឆ្នាំ2020) និងសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្មកម្ពុជា (លេខ 3885 ចុះថ្ងៃទី24 ខែធ្នូ ឆ្នាំ2020)។*
14. *អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ខែមេសា ឆ្នាំ2022។*
15. *ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) គឺជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងប្រទេសសមាជិកអាស៊ានទាំង 10 ប្រទេស (ប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ វៀតណាម) និងដៃគូកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួន 5 របស់កម្ពុជា (ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ អូស្ត្រាលី និងនូវែលហ្សេឡង់)។- (តំណភ្ជាប់ទៅកាន់ប្រភព).*
16. *ឯកសារស្រាវជ្រាវគោលនយោបាយរបស់ធនាគារពិភពលោក ខែកុម្ភៈ ឆ្នាំ2022 "ការប៉ាន់ស្មានលើឥទ្ធិពលសេដ្ឋកិច្ច និងការបែកចាយនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់" ទំព័រ 18។*
17. *អង្គការពលកម្មអន្តរជាតិ ឆ្នាំ2022 "និន្នាការការងារ ប្រាក់ឈ្នួល និងផលិតភាពនៅក្នុងវិស័យកាត់ដេរក្នុងតំបន់អាស៊ី" អង្គការពលកម្មអន្តរជាតិ ប្រទេសថៃ។*
18. *គម្រោងវិនិយោគសម្តៅទៅលើគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បន្ថែម (មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកទឹកចិត្តសារពើពន្ធ) និងគម្រោងវិនិយោគមានការធានា (មិនមានការលើកទឹកចិត្តសារពើពន្ធ)។*

19. *ការអនុវត្តអនុក្រឹត្យពាក់ព័ន្ធ ដើម្បីគាំទ្រដល់ច្បាប់នេះ អាចនឹងចេញនាពេលឆាប់ៗនេះ។*
20. *ឯកសារសង្ខេបពិសេសនៃច្បាប់ស្តីពីការវិនិយោគថ្មី (បានប្រកាសឱ្យប្រើប្រាស់កាលពីខែតុលា ឆ្នាំ2021) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហការជាមួយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា។*
21. *ច្បាប់ស្តីពីការវិនិយោគថ្មីរបស់កម្ពុជា បានប្រកាសឱ្យប្រើនៅថ្ងៃទី15 ខែតុលា ឆ្នាំ2021 (មាត្រា 24)។*
22. *ច្បាប់ស្តីពីការវិនិយោគថ្មីរបស់កម្ពុជា បានប្រកាសឱ្យប្រើនៅថ្ងៃទី15 ខែតុលា ឆ្នាំ2021 (មាត្រា 12)។*
23. *អនុក្រឹត្យរបស់រដ្ឋាភិបាល (លេខ 120 ចុះថ្ងៃទី20 ខែមិថុនា ឆ្នាំ2022) ស្តីពី "ការរៀបចំ និងប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី/ខេត្ត"។*
24. *អង្គការពលកម្មអន្តរជាតិ ឆ្នាំ2022 "និន្នាការការងារ ប្រាក់ឈ្នួល និងផលិតភាពនៅក្នុងវិស័យកាត់ដេរក្នុងតំបន់អាស៊ី" អង្គការពលកម្មអន្តរជាតិ ប្រទេសថៃ។*
25. *ធុរកិច្ចនៅអាស៊ី (តំណភ្ជាប់ទៅកាន់អត្ថបទ).*
26. *ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើស្ថិតិពី ក្រសួងពាណិជ្ជកម្ម។*
27. *យោងតាមរយៈពេលនចំនួនការងារជាមធ្យមនៃឆ្នាំដែលបានបង្ហាញ។*
28. *ការបាត់បង់ការងារ 10,200 ការងារនៅឆ្នាំ2020 និង 33,500 ការងារនៅឆ្នាំ2021 = ការបាត់បង់ការងារចំនួន 43,600 ការងារនៅទូទាំងវិស័យទាំងមូល (ដកការបង្កើតការងារ)។*
29. *សារព័ត៌មានភ្នំពេញប៉ុស្តិ៍ (ចុះថ្ងៃទី10 ខែមករា ឆ្នាំ2022) សម្រង់សម្តីពីប្រធានសមាគមផលិតស្បែកជើងកម្ពុជា (កង្វះខាតកម្លាំងពលកម្មក្នុងវិស័យផលិតស្បែកជើង ផលិតផលធ្វើដំណើរ៖ សមាគម).*
30. *ការគណនាផ្អែកលើស្ថិតិរបស់ក្រសួងពាណិជ្ជកម្ម។*
31. *គិតត្រឹមសេចក្តីប្រកាសនៅថ្ងៃទី22 ខែកញ្ញា ឆ្នាំ2022។ កម្មករនិយោជិត នឹងនៅតែបន្តទទួលបានអត្ថប្រយោជន៍ផ្សេងៗ៖ ប្រាក់ឧបត្ថម្ភ $7 ក្នុងមួយខែសម្រាប់ការធ្វើដំណើរ និងស្នាក់នៅ $10 សម្រាប់ប្រាក់រង្វាន់លើកទឹកចិត្តវត្តមានទៀងទាត់ក្នុងមួយខែ $0.50 ក្នុងមួយថ្ងៃសម្រាប់អាហារ ឬផ្តល់ជូនអាហារឥតគិតថ្លៃយ៉ាងតិចត្រឹមចំនួនទឹកប្រាក់នោះ ប្រសិនបើកម្មករនិយោជិតធ្វើការថែមម៉ោង  $11 ក្នុងមួយខែសម្រាប់ការទូទាត់អតីតភាពការងារសម្រាប់កម្មករនិយោជិតដែលបានបម្រើការងារចាប់ពីឆ្នាំទី2 ដល់ឆ្នាំទី11។ ប្រាក់ឈ្នួលអប្បបរមាថ្មីឆ្នាំ2023 បានបន្ថែមជាមួយនូវអត្ថប្រយោជន៍ផ្សេងៗទៀត ដែលមានន័យថា កម្មករនិយោជិតទទួលបានចន្លោះពី $217 - $228 ក្នុងមួយខែចំពោះសំណងជាមធ្យម។*
32. *ការគណនាដោយប្រើប្រាស់តម្លៃ និងសន្ទស្សន៍តម្លៃទំនិញអ្នកប្រើប្រាស់ឆ្នាំ2017 ពី វិទ្យាស្ថានជាតិស្ថិតិកម្ពុជា។*
33. *ប្រាក់ឈ្នួលអប្បបរមា គឺត្រូវបានបម្លែងទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ (អត្រាមធ្យមក្នុងអំឡុងរយៈពេលពីខែមករា-កក្កដា ឆ្នាំ2022)។*
34. *យោងតាមលិខិត (លេខ 026/22 ចុះថ្ងៃទី23 ខែមិថុនា ឆ្នាំ2022) ពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនដល់ភាគីសាមីទាំងអស់។*
35. *"ឥទ្ធិពលរលកនៃខ្សែសង្វាក់ផ្គត់ផ្គង់៖ របៀបដែលជំងឺកូវីដ 19 ជះឥទ្ធិពលដល់កម្មករនិយោជិត និងរោងចក្រកាត់ដេរនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក" ទីក្រុងហ្សឺណែវ៖ អង្គការពលកម្មអន្តរជាតិ ឆ្នាំ2020*
36. *នៅថ្ងៃទី10 ខែតុលា ឆ្នាំ2022 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម  អង្គការពលកម្មអន្តរជាតិ និង សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (អតីត សមាគមរោងចក្រកាត់ដេរនៅកម្ពុជា) បានត្រួតពិនិត្យកម្មវិធីនេះរហូតដល់ឆ្នាំ2027។*
37. *ទិន្នន័យអំពីអនុលោមភាពថ្មីបំផុត អាចរកបានពី៖https://annual-report.betterwork.org/2019/data-portal/ISO3/country/Cambodia*
38. *Ibidem*
39. *សូមមើលផងដែរ ឧទាហរណ៍៖ Antolin, A. et al (ឆ្នាំ2020) តើអនុលោមភាពសង្គមជាយុទ្ធសាស្ត្រឈ្នះ-ឈ្នះសម្រាប់កម្មករនិយោជិត និងក្រុមហ៊ុនមែនដែរឬទេ? ភស្តុតាងពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។ ILO-IFC៖ ឯកសារពិភាក្សាអំពីការងារល្អប្រសើរ លេខ 39;*

    *Brown, D. et al (ឆ្នាំ2013) តើមានករណីប្រសិទ្ធភាពសម្រាប់បទដ្ឋានពលកម្មអន្តរជាតិដែរឬទេ? ILO-IFC៖ ឯកសារពិភាក្សាអំពីការងារល្អប្រសើរ លេខ 12;  Lawreniuk, S., Brickell, K., & McCarthy, L. (ឆ្នាំ2022) ការកសាងឆ្ពោះទៅមុខកាន់តែយ៉ាប់យ៉ឺនជាងមុន៖ របៀបដែលជំងឺកូវីដ 19 បានបង្កើនការប្រកួតប្រជែង ដល់កម្រិតទាបបំផុតនៅក្នុងឧស្សាហកម្មកាត់ដេរសកល។ Royal Holloway, សាកលវិទ្យាល័យទីក្រុងឡុងដ៍;*

    *Robertson, R. (ឆ្នាំ2019) ការឆ្លុះបញ្ចាំងឱ្យឃើញពី៖ តម្លាភាព និងអនុលោមភាព - ភស្តុតាងពីប្រទេសកម្ពុជា។ ILO-IFC៖ ឯកសារពិភាក្សាអំពីការងារល្អប្រសើរ លេខ 29*
40. *Babbitt, L. Et al (ឆ្នាំ2020) ការបៀតបៀនផ្លូវភេទ៖ មូលហេតុ និងការកែតម្រូវ ILO-IFC៖ ឯកសារពិភាក្សាអំពីការងារល្អប្រសើរ លេខ 38 អាចរកបានពី៖ betterwork.org/portfolio/discussion-paper-38-sexual-harassment-causes-and-remediation/*
41. *Lawreniuk, S., Brickell, K., & McCarthy, L. (ឆ្នាំ2022) ការកសាងឆ្ពោះទៅមុខកាន់តែយ៉ាប់យ៉ឺនជាងមុន៖ របៀបដែលជំងឺកូវីដ 19 បានបង្កើនការប្រកួតប្រជែងដល់កម្រិតទាបបំផុតនៅក្នុងឧស្សាហកម្មកាត់ដេរសកល។ Royal Holloway, សាកលវិទ្យាល័យទីក្រុងឡុងដ៍*
42. *សារព័ត៌មានខ្មែរថាមស៍ (ចុះថ្ងៃទី10 ខែសីហា ឆ្នាំ2022) "កម្ពុជាជួបការលំបាក ប៉ុន្តែជាប់ចំណាត់ថ្នាក់លេខពីរនៅក្នុងសន្ទស្សន៍ Nikkei ស្តីពីការស្តារប្រទេសឡើងវិញពីជំងឺកូវីដ 19" , (តំណភ្ជាប់ទៅកាន់អត្ថបទ).*
43. *គ្រប់លេខយោងទាំងអស់ សម្តៅទៅលើរោងចក្រនាំចេញដែលបានចុះបញ្ជីផ្លូវការនៅក្រសួងពាណិជ្ជកម្មប៉ុណ្ណោះ។ រោងចក្រម៉ៅការបន្តមួយចំនួន ដែលមិនបាននាំចេញដោយផ្ទាល់ ឬបានចុះបញ្ជីជាផ្លូវការ អាចនឹងមិនបានរួមបញ្ចូល និង/ឬកត់ត្រាបានត្រឹមត្រូវនោះទេ។ ការបិទរោងចក្រដែលសម្តៅនៅក្នុងចំណុចនេះ រួមបញ្ចូលរោងចក្រដែលបានបិទទ្វារ/ផ្អាកបណ្តោះអាសន្ន កំពុងបិទ និងបិទជាអចិន្ត្រៃយ៍។*
44. *"ការវាយតម្លៃតម្រូវការរបស់កម្មករនិយោជិតកាត់ដេរក្នុងអំឡុងពេលនៃជំងឺកូវីដ 19" អនុវត្តដោយអង្គការ ឃែរអន្តរជាតិ នៅកម្ពុជា (ខែកក្កដា ឆ្នាំ2020)។*
45. *សេចក្តីណែនាំរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) លេខ 045/20 ចុះថ្ងៃទី17 ខែមេសា ឆ្នាំ2020 (តំណភ្ជាប់) និងសេចក្តីប្រកាសសារព័ត៌មានរបស់រដ្ឋាភិបាល (ចុះថ្ងៃទី29 ខែមិថុនា ឆ្នាំ2021) ស្តីពីវិធានការបន្ថែមដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ 19 ទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ និងដើម្បីស្តារឡើងវិញ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ 19 (ជុំទី 9)។*
46. *ស្ថិតិផ្លូវការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គម្រោងចែកប្រាក់ បានបញ្ចប់នៅខែមករា ឆ្នាំ2022 ដោយផ្អែកលើលិខិតរួមរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង បេឡាជាតិរបបសន្តិសុខសង្គម (ចុះថ្ងៃទី18 ខែមករា ឆ្នាំ2022)។*
47. *សេចក្តីប្រកាសសារព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ថ្ងៃទី11 ខែឧសភា ឆ្នាំ2021) ស្តីពី កម្មវិធី "ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់"  និង "សម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ក្នុងព្រឹត្តិការណ៍ 20 កុម្ភៈ 2021"។*
48. *Ibidem*
49. *Ibidem*
50. *ស្ថិតិផ្លូវការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានវិញ្ញាបនបត្រកម្រិត 1 រយៈពេល 4 ខែ។*
51. *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ឆ្នាំ2022–2027 (ទំព័រ iv)។*

52. *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើររបស់កម្ពុជា ឆ្នាំ2022–2027 ( ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ SNEC ខែកុម្ភៈ ឆ្នាំ2022 )។*
53. *អគ្គនាយកដ្ឋានពន្ធដារកម្ពុជា អនុក្រឹត្យលេខ196 ស្តីពីដែនកំណត់នៃពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធលើប្រាក់បៀវត្សប្រចាំខែ ថ្ងៃទី22 ខែកញ្ញា ឆ្នាំ2022*
54. *សារាចរណែនាំលេខ  002 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( ចុះថ្ងៃទី20 ខែមករា ឆ្នាំ2015 ) ស្តីពី "ការអនុវត្តកាតព្វកិច្ចពន្ធ និង អត្ថប្រយោជន៍បន្ថែម" និងលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( លេខ 011 ចុះថ្ងៃទី6 ខែតុលា ឆ្នាំ2016 ) ស្តីពី "សារាចរណែនាំស្តីពីការអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកទៅលើអត្ថប្រយោជន៍បន្ថែម"។*
55. *អនុក្រឹត្យលេខ196 ចុះថ្ងៃទី22 ខែកញ្ញា ឆ្នាំ2022 នឹងមានសុពលភាពអនុវត្តនៅថ្ងៃទី1 ខែមករា ឆ្នាំ2023។*
56. *សាររបស់នាយករដ្ឋមន្ត្រីក្នុងអំឡុងទិវាពលកម្មអន្តរជាតិលើកទី136 ថ្ងៃទី1 ខែឧសភា ឆ្នាំ2022។*
57. *សេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី6 ខែកញ្ញា ឆ្នាំ2017 នៅសេចក្តីថ្លែងការណ៍លើទូរទស្សន៍អំពីលិខិត TVK និងលិខិតរបស់ បសស ចុះថ្ងៃទី12 ខែមិថុនា ឆ្នាំ2017 ស្តីពី "សិទ្ធិទទួលបានប្រាក់សម្រាប់ការឈប់សម្រាកមាតុភាពសម្រាប់សមាជិកដែលបានចុះឈ្មោះរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលសម្រាលកូននៅមណ្ឌលសុខភាពដោយមិនមានការព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម"។*
58. *លិខិត លេខ154/22 ចុះថ្ងៃទី27 ខែឧសភា ឆ្នាំ2022*
59. *អនុក្រឹត្យរបស់រដ្ឋាភិបាល លេខ 01 ចុះថ្ងៃទី6 ខែមករា ឆ្នាំ2016។*
60. *ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី "កាលបរិច្ឆេទចាប់ផ្តើមនៃភាគទានសន្តិសុខសង្គមចំពោះគម្រោងសោធនតាមរយៈរបបកាតព្វកិច្ច និងស្ម័គ្រចិត្ត" ( លេខ 170/22 ចុះថ្ងៃទី5 ខែកក្កដា ឆ្នាំ2022 ) និងស្តីពី "ការអនុវត្តគម្រោងសន្តិសុខសង្គមលើសោធនសម្រាប់បុគ្គលនៅក្រោមបញ្ញត្តិនៃច្បាប់ការងារកម្ពុជា" ( លេខ 165/22 ចុះថ្ងៃទី28 ខែមិថុនា ឆ្នាំ2022 )។*
61. *អនុក្រឹត្យរបស់រដ្ឋាភិបាល ( លេខ 32 ចុះថ្ងៃទី4 ខែមីនា ឆ្នាំ2021 ) ស្តីពី "សន្តិសុខសង្គមលើសោធនសម្រាប់បុគ្គលនៅក្រោមបញ្ញត្តិនៃច្បាប់ការងារ"។*
62. *តួលេខផ្លូវការពីសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ( UNCTAD ទាញយកនៅថ្ងៃទី16 ខែកក្កដា ឆ្នាំ2022 )។*
63. *តួលេខផ្លូវការពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ( GDEC ) និង វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា។*
64. *សេចក្តីប្រកាសសារព័ត៌មានរបស់គណៈកម្មការអឺរ៉ុបស្តីពីប្រព័ន្ធអនុគ្រោះអ្វីគ្រប់យ៉ាង លើកលែងតែអាវុធរបស់កម្ពុជា នៅថ្ងៃទី12 ខែសីហា ឆ្នាំ2020 ( តំណភ្ជាប់ទៅកាន់ សេចក្តីប្រកាសសារព័ត៌មាន ).*



# ឯកសារសង្ខេបអំពីវិស័យកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ នៅកម្ពុជា


អ្នកនិពន្ធ ៖ ហួត ជា, ទីប្រឹក្សាយោបល់



កិច្ចសហប្រតិបត្តិការជាមួយ ៖

- គម្រោង FABRIC Cambodiaអនុវត្តដោយទីភ្នាក់ងារ អាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ( GIZ ) តាមរយៈជំនួយរបស់ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់ សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ ( BMZ )
- អង្គការអន្តរជាតិខាងការងារ ( ILO )
- សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និង ផលិតផលធ្វើដំណើរនៅកម្ពុជា( TAFTAC )

បោះពុម្ពដោយ ៖ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា

ទីស្នាក់ការដើម
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ផ្ទះលេខ ៣0E3 មហាវិថីព្រះនរោត្តម ១២២២០
អគារ BRED Bank ជាន់ទី៣ សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

+855 (0)23 96 41 41
info@eurocham-cambodia.org
www.eurocham-cambodia.org

រចនាដោយ ៖ លឹម សុខអ៊ីម

កាលបរិច្ឆេទ ៖ ខែវិច្ឆិកា ឆ្នាំ២០២២